# ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំ អនាម័យទាំងស្រុង (SLH) ៖ នវានុវត្តន៍ និងចំណេះដឹង




## ការជំរុញការចូលរួមរបស់បុរស និងក្មេងប្រុស ក្នុងកម្មវិធីអនាម័យ

Sue Cavill, Joanna Mott and Paul Tyndale-Biscoe, with
Matthew Bond, Chelsea Huggett and Elizabeth Wamera

ខែ កញ្ញា ឆ្នាំ ២០២០

The Sanitation Learning Hub at institute of development studies
https: //sanitationlearninghub.org

the sanitation learning hub

## អំពីមជ្ឈមណ្ឌលចំណេះដឹង នៃសហគមន៍ដឹកនាំអនាម័យទាំងស្រុង

វិទ្យាស្ថានអភិវឌ្ឍន៍សិក្សា បានគាំទ្រដល់កម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង (SLH) តាំងពីចាប់ផ្តើមដំបូង។ SLH បានក្លាយជាចលនាអន្តរជាតិមួយ ដែលបណ្តាលឲ្យ វិទ្យាស្ថានអភិវឌ្ឍន៍សិក្សាត្រូវបានទទួលស្គាល់ថាជា មជ្ឈមណ្ឌលចំណេះដឹង។

មជ្ឈមណ្ឌលចំណេះដឹង មានគោលបំណងស្វែងយល់ពីតថភាពពិតនៅមូលដ្ឋានស្តីពីការអនុវត្ត SLH ក៏ដូចជារៀនសូត្រ ចែករំលែក និងលើកកម្ពស់ការអនុវត្តល្អ គំនិត និងនវានុវត្តន៍ដែលជំរុញឱ្យមាននិរន្តរភាព និងវិសាលភាព។ យើងខិតខំធ្វើយ៉ាងណាឲ្យសហគមន៍ SLH រក្សាទំនាក់ទំនងល្អនិងទទួលបានការផ្តល់ព័ត៌មានត្រឹមត្រូវព្រមទាំងផ្តល់កន្លែងសម្រាប់ការឆ្លុះបញ្ចាំង ការរៀនសូត្រជាបន្តបន្ទាប់ និងការផ្លាស់ប្តូរចំណេះដឹង។ យើងធ្វើការដោយសហការជាមួយអ្នកអនុវត្តន៍ អ្នកតាក់តែងគោលនយោបាយ អ្នកស្រាវជ្រាវ និងអ្នកពាក់ព័ន្ធផ្សេងទៀតដែលធ្វើការក្នុងផ្នែកអភិវឌ្ឍន៍ អនាម័យ និងសហគមន៍ពាក់ព័ន្ធ។

គោលដៅរួមរបស់មជ្ឈមណ្ឌលចំណេះដឹងគឺដើម្បីរួមចំណែកពង្រឹងសេចក្តីថ្លៃថ្នូរ សុខភាព និងសុខុមាលភាពរបស់កុមារ ស្ត្រី និងបុរសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលកំពុងប្រឈមនឹងផលវិបាកនៃការគ្មានឬកង្វះខាតសេវាអនាម័យ។

គម្របមុខ ៖

ជនភៀសខ្លួនមកពីប្រទេសស៊ូដង់ខាងត្បូង បានបង្រៀនកូនប្រុសអាយុ៦ឆ្នាំរបស់គាត់ ពីរបៀបលាងសម្អាតដៃឱ្យបានត្រឹមត្រូវដោយប្រើធុងទឹកលាងដៃកែច្នៃដោយខ្លួនឯង ដែលស្ថិតនៅខាងក្រៅកន្លែងស្នាក់នៅរបស់ខ្លួនក្នុងជំរំជនភៀសខ្លួន Bidibidi ស្ថិតក្នុងស្រុក Yumbe ប្រទេសអ៊ុយហ្គង់ដាខាងជើង កាលពីខែ មីនា ឆ្នាំ ២០១៧។

ក្រេឌីត៖ UNICEF/ JIRO OSE

# ការជំរុញការចូលរួមរបស់បុរស និងក្មេងប្រុស
# ក្នុងកម្មវិធីអនាម័យ

**Sue Cavill, Joanna Mott and Paul Tyndale-Biscoe, with Matthew Bond, Chelsea Huggett and Elizabeth Wamera**

ការដកស្រង់ត្រឹមត្រូវ៖ ការ៉ិល, ស., ម៉ត្ត, ច. និងទីនដេល-ប៊ីសក្ធ, ភ., ជាមួយ ប៊ិន, ម., ហាកហ្គិត, ខ. និងវ៉ាមីវ៉ា, អ. (២០១៨) 'ការជំរុញការចូលរួមរបស់បុរស និងក្មេងប្រុសក្នុងកម្មវិធីអនាម័យ', ព្រំដែននៃមជ្ឈមណ្ឌលចំណេះដឹងអនាម័យ៖ នវានុវត្តន៍ និងចំណេះដឹង ១១, ប្រាយតុន៖ IDS, DOI: 10.19088/SLH.2020.002

បោះពុម្ពលើកទី១ នៅឆ្នាំ ២០១៨
រក្សាសិទ្ធិថតចម្លង © វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍ ឆ្នាំ ២០១៨
ការរក្សាសិទ្ធិមួយចំនួនទៀត៖ សម្រាប់ព័ត៌មានលម្អិត សូមមើលអាជ្ញាប័ណ្ណសិទ្ធិថតចម្លង។

ISBN 978-1-78118-704-3

DOI: 10.19088/SLH.2020.002
(https://doi.org/10.19088/SLH.2020.002)

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង ៖
The Sanitation Learning Hub, Institute of Development Studies, University of Sussex, Brighton, BN1 9RE
Tel: +44 (0)1273 606261
Email: SLH@ids.ac.uk
Web: https://sanitationlearninghub.org/

កម្រងឯកសារនេះត្រូវបានផ្តល់អាជ្ញាប័ណ្ណក្រោមអាជ្ញាប័ណ្ណ the Creative Commons Attribution-Non-Commercial-NoDerivs 3.0 Unported License (http://creativecommons.org/licenses/by-nc-nd/3.0/).

*ការសំអាង៖ អ្នកត្រូវសំអាងកម្រងឯកសារនេះតាមរបៀបដែលកំណត់ដោយអ្នកនិពន្ធ ឬអ្នកផ្តល់អាជ្ញាប័ណ្ណ។ មិនមែនសម្រាប់គោលបំណងពាណិជ្ជកម្ម៖ អ្នកមិនអាចប្រើប្រាស់ឯកសារនេះសម្រាប់គោលបំណងពាណិជ្ជកម្មបានទេ។*
*គ្មានការចម្លងតាម ៖ អ្នកមិនអាចកែប្រែ ផ្ទេរ ឬបំពេញបន្ថែមពីលើកម្រងឯកសារនេះទេ។*

អ្នកប្រើប្រាស់អាចថតចម្លង ចែកចាយ ដាក់បង្ហាញ បកប្រែ ឬយកកម្រងឯកសារនេះទៅប្រើប្រាស់ដោយមិនចាំបាច់មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ។ សម្រាប់ការប្រើប្រាស់ឡើងវិញ ឬការចែកចាយ អ្នកត្រូវបញ្ជាក់ឱ្យបានច្បាស់ពីលក្ខខណ្ឌអាជ្ញាប័ណ្ណនៃកម្រងឯកសារនេះ។ ប្រសិនបើអ្នកប្រើប្រាស់កម្រងឯកសារនេះ យើងស្នើឱ្យអ្នកយោងតាមគេហទំព័រ SLH (https://sanitationlearninghub.org) រួចបញ្ជូនសំណៅចម្លងកម្រងឯកសារនេះ ឬតំណភ្ជាប់សម្រាប់ការប្រើប្រាស់តាមអនឡាញ ទៅអាសយដ្ឋាន៖ The Sanitation Learning Hub, Institute of Development Studies, University of Sussex, Brighton, BN1 9RE, UK (SLH@ids.ac.uk)។

ឯកសារនេះត្រូវបានផ្តល់ហិរញ្ញប្បទានដោយទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត Sida។ ទស្សន៍:ដែលបានលើកឡើងក្នុងឯកសារនេះមិនឆ្លុះបញ្ចាំងទស្សនៈរបស់ Sida ឡើយ។
ការទទួលខុសត្រូវលើខ្លឹមសារឯកសារនេះជាបន្ទុកទាំងស្រុងរបស់អ្នកនិពន្ធ។

# សេចក្តីថ្លែងអំណរគុណ

សូមអរគុណជាអនេកចំពោះដៃគូដែលបានជួយត្រួតពិនិត្យឯកសារនេះ៖

- Naomi Vernon និងJamie Myers, the Sanitation Learning Hub at IDS
- Jerker Edström, IDS
- Ross Kidd, Kristie Urich និង Juliet ដែលបានផ្តល់មតិយោបល់ និងការណែនាំបន្ថែម។

FHDesigns
Development, Engineering & Design

WSSCC
WATER SUPPLY & SANITATION
COLLABORATIVE COUNCIL

WaterAid

# ការជំរុញការចូលរួមរបស់បុរស និងក្មេងប្រុស ក្នុងកម្មវិធីអនាម័យ

## ពាក្យបច្ចេកទេស

តារាងខាងក្រោមពន្យល់ពាក្យគន្លឹះមួយចំនួនដែលប្រើក្នុងឯកសារនេះ

| | |
|---|---|
| **យេនឌ័រ** | ផ្នត់គំនិតដែលត្រូវបានបង្កើតឡើងក្នុងបទដ្ឋានសង្គមនិងវប្បធម៌ស្តីពីលក្ខណៈជាបុរស ឬស្ត្រី (និងក្មេងប្រុសឬក្មេងស្រីទៅតាមប្រភេទផ្សេងៗ (អាយុ វណ្ណៈ ជាតិពន្ធុ។ល។) ក្នុងបរិបទ និងពេលវេលាជាក់លាក់។ |
| **ការវិភាគយេនឌ័រ** | ការពិនិត្យល្អិតល្អន់ និងជាប្រព័ន្ធលើភាពខុសគ្នានៃឧបសគ្គ និងឱកាសសម្រាប់បុគ្គលម្នាក់ៗ ឬក្រុមដោយផ្អែកលើយេនឌ័ររបស់ពួកគេ។ |
| **ការរើសអើងយេនឌ័រ** | ការប្រព្រឹត្តជាប្រព័ន្ធដោយគ្មានការអនុគ្រោះចំពោះបុគ្គលដោយសារតែយេនឌ័ររបស់ពួកគេ។ |
| **កញ្ចក់យេនឌ័រ** | ទស្សនៈដែលផ្តោតការយកចិត្តទុកដាក់ជាពិសេសលើភាពខុសគ្នា និងទំនាក់ទំនងយេនឌ័រ។ |
| **បទដ្ឋានយេនឌ័រ** | ការរំពឹងទុក និងជំនឿជារួមស្តីពីរបៀបដែលស្ត្រី បុរស ក្មេងស្រី និងក្មេងប្រុសគួរប្រព្រឹត្ត និងទំនាក់ទំនងក្នុងមជ្ឈដ្ឋានសង្គមជាក់លាក់ និងក្នុងដំណាក់កាលផ្សេងៗនៃជីវិតរបស់ពួកគេ។ |
| **ទំនាក់ទំនងយេនឌ័រ** | ទំនាក់ទំនងអំណាចដែលត្រូវបានបង្កើតឡើងក្នុងសង្គម រវាងបុរស និងស្ត្រី ក្មេងប្រុស និងក្មេងស្រី។ |
| **ភេទ** | ស្ថានភាពជីវសាស្ត្ររបស់មនុស្សម្នាក់ ដែលកំណត់ជាប្រុស ស្រី ឬអភេទ។ |
| **ភាពប្រទាក់ក្រឡាគ្នា** | ចំណុចនេះមានន័យថា អត្តសញ្ញាណសង្គមដែលប្រទាក់ក្រឡាគ្នា (ស្ត្រី និងប្រុសផ្សេងគ្នា ដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងពេលតែមួយ ដោយវណ្ណៈសង្គម ជាតិពន្ធុ អាយុ សាសនា។ល។) ពាក់ព័ន្ធនឹងគ្នា ឬ "សហាការគ្នា" ក្នុងប្រព័ន្ធប្រទាក់ក្រឡាគ្នាដែលពោរពេញដោយបុព្វសិទ្ធិ និងការគៀបសង្កត់ផ្អែកតាមយេនឌ័រ វណ្ណៈ ត្រកូលពូជសាសន៍ ផ្លូវភេទ សមត្ថភាព សាសនា។ល។ ចំណុចនេះជួយឱ្យយើងយល់ពីទំនាក់ទំនង និងអន្តរកម្មនៃទម្រង់ផ្សេងៗនៃការគៀបសង្កត់ និងការផាត់ចេញ ដូចជា ការស្អប់ស្ត្រី ការប្រកាន់ពូជសាសន៍ ឥស្សរជននិយម ការស្អប់/ខ្លាចមនុស្សស្រឡាញ់ភេទដូចគ្នា។ល។ (Birchall et al. 2016)។ |

## សេចក្តីផ្តើម

ឯកសារដែលមានចំណងជើងថា "ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង" ចែករំលែក និងផ្អែកលើការរៀនសូត្រពីការពិនិត្យឡើងវិញលើឯកសារមានស្រាប់ ដោយស្វែងយល់ពីឧទាហរណ៍នៃអាកប្បកិរិយា និងតួនាទីយេនឌ័ររបស់បុរស និងក្មេងប្រុសក្នុងវិស័យអនាម័យ។ ចំណុចគួរឱ្យចាប់អារម្មណ៍នោះគឺកម្រិតដែលការជំរុញការចូលរួមរបស់បុរស និងក្មេងប្រុសក្នុងដំណើរការអនាម័យ ដែលនាំឱ្យមានការផ្លាស់ប្តូរដែលមាននិរន្តរភាព នៅក្នុងគ្រួសារ និងសហគមន៍និងការកាត់បន្ថយវិសមភាពយេនឌ័រ។

ការពិនិត្យឡើងវិញនេះផ្តោតលើបុរស និងក្មេងប្រុស៖ របៀបដែលជំរុញការចូលរួមរបស់ពួកគេ (របៀបដែលមិនជំរុញ) របៀបប្រមូលផ្តុំពួកគេជាសម្ព័ន្ធក្នុងការផ្លាស់ប្តូរលទ្ធផលអនាម័យ និងបញ្ហាដែលពួកគេរួមចំណែក និងជួបប្រទះ។

## យេនឌ័រក្នុងកម្មវិធីអនាម័យ

ការពិភាក្សាពីយេនឌ័រក្នុងវិស័យអនាម័យ ច្រើនផ្តោតលើតួនាទី គោលជំហរ ឬផលប៉ះពាល់លើស្រ្តី និងក្មេងស្រី។ ការផ្តោតដូច្នេះមានសារៈសំខាន់ណាស់ ក្នុងការបង្កើនលទ្ធផលផ្នែកយេនឌ័រក្នុងកម្មវិធីទឹកស្អាត និងអនាម័យ (WASH) ព្រោះស្រ្តី និងក្មេងស្រីជាអ្នករ៉ាប់រងបន្ទុកការងារទឹកស្អាត និងអនាម័យធ្ងន់ជាងគេ ប៉ុន្តែជាញឹកញាប់ស្រ្តី និងក្មេងស្រីត្រូវបានផាត់ចេញពីការរៀបចំផែន ការផ្តល់សេវា និងការពិនិត្យតាមដានសកម្មភាពទឹកស្អាត និងអនាម័យក្នុងសហគមន៍ ដោយសារតែស្រ្តី និងក្មេងស្រីមិនសូវមានអំណាចធនធាន ពេលវេលា និងឋានៈសង្គម ដូចដៃគូបុរសរបស់គេ។ ទោះជាយ៉ាងណា កិច្ចខិតខំប្រឹងប្រែងនាពេលបច្ចុប្បន្នក្នុងការបង្កើនអនាម័យ និងផ្លាស់ប្តូរបទដ្ឋានសង្គមប្រហែលជាមិនបានជំរុញការចូលរួមរបស់បុរស និងក្មេងប្រុស ឲ្យបានសកម្ម និងតាមវិធីដែលមានប្រសិទ្ធភាពបំផុតនោះទេ។ មានចំណុចជាច្រើនទៀតដែលត្រូវស្វែងយល់ពាក់បន្ថែមស្តីពីតួនាទីជាក់ស្តែងរបស់បុរស និងក្មេងប្រុសក្នុងការការប្រើប្រាស់អនាម័យប្រកបដោយសុវត្ថិភាព និងមានលក្ខណៈកែលម្អ។ ហើយប្រសិនចាំបាច់ តើគួរកែលំអយុទ្ធសាស្រ្តជំរុញការចូលរួមរបៀបណាដើម្បីឲ្យកិច្ចខិតខំប្រឹងប្រែងកាន់តែជោគជ័យ។

ការចូលដោយសកម្ម និងវិជ្ជមានរបស់បុរស និងក្មេងប្រុស គឺជាការរបង្កើនលទ្ធផលអនាម័យ ហើយក៏ជាសក្តានុពលមួយសម្រាប់ការបែងចែកឡើងវិញ នូវកិច្ចការ និងការទទួលខុសត្រូវក្នុងផ្ទះដែលមិនមានលក្ខណៈស្មើភាពគ្នា ពីស្រ្តីទៅបុរសវិញ។ លទ្ធផលប៉ាន់ស្មានគឺមានទាំងភាពជាក់លាក់ និងលក្ខណៈយុទ្ធសាស្រ្ត។ ភាពជាក់លាក់គឺការធានាថា បុរស និងក្មេងប្រុសអនុវត្តអនាម័យដែលមានសុវត្ថិភាព និងរួមចំណែកធានាថា សហគមន៍នៅតែគ្មានការបន្ទោរបង់ពាសវាលពាសកាលក្នុងរយៈពេលវែង។ លក្ខណៈយុទ្ធសាស្រ្ត គឺជាបរិយាកាសអនុគ្រោះឲ្យឱ្យស្រ្តីមានសំឡេងកាន់តែរឹងមាំក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងដើម្បីឱ្យបុរសគាំទ្រតួនាទីស្រ្តីក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងគ្រួសារ និងសហគមន៍។ បើទោះបីជាមានការទទួលស្គាល់ថា កម្មវិធីសហគមន៍

ដឹកនាំអនាម័យទាំងស្រុង (SLH) ឬកម្មវិធីអនាម័យផ្សេងទៀត មិនអាចដោះស្រាយវិសមភាពសង្គម និងបញ្ហាសង្គម តែម្នាក់ឯងបានក្តី កម្មវិធីទាំងនេះអាចត្រូវបានអនុវត្តតាមរបៀបដែលគាំទ្រការផ្លាស់ប្តូរទំនាក់ទំនងយេនឌ័រ ដូចជា តាមរយៈការធ្វើយ៉ាងណាឱ្យដំណើរការធ្វើសេចក្តីសម្រេចចិត្តកាន់តែមានសមធម៌ និងមិនសូវរើសអើង ហើយមិនសូវបន្ទាបតម្លៃស្ត្រី ដែលសំដៅលើការបង្កើនបុព្វសិទ្ធិរបស់ស្ត្រីឱ្យស្មើនឹងបុព្វសិទ្ធិរបស់បុរស។

## តើត្រូវផ្លាស់ប្តូរអ្វីខ្លះ?

កម្មវិធីអនាម័យដែលមានបេសកកម្មផ្លាស់ប្តូរឥរិយាបថដែលគ្មានអនាម័យ មានតែករណីមួយចំនួនប៉ុណ្ណោះដែលមានបំណងផ្លាស់ប្តូរតួនាទីយេនឌ័រ និងចលនាអំណាចរវាងបុរស និងស្ត្រីនៅកម្រិតគ្រួសារ និងសហគមន៍។ ដូច្នេះហើយ ដំណើរការអនាម័យអាចនឹងបង្កើនភាពលម្អៀងនៃយេនឌ័រដែលពាក់ព័ន្ធនឹងតួនាទីថែទាំរបស់ស្ត្រីដែលត្រូវបានកំណត់ដោយសង្គម និងការជំរុញទឹកចិត្តដោយខ្លួនឯងឱ្យប្រកាន់ឥរិយាបថអនាម័យ។

ផ្នែកផ្សេងទៀតនៃចំណុចនេះ សំដៅរកបញ្ហាមួយចំនួនដែលពាក់ព័ន្ធនឹងឥរិយាបថ និងការអនុវត្តអនាម័យរបស់បុរស។

## សមាសភាគរបស់បុរសក្នុងព្រឹត្តិការណ៍កម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង

នៅតាមបណ្តាប្រទេសមួយចំនួន ការជំរុញឱ្យបុរសចូលរួមក្នុងវគ្គបំផុសកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង ឬការធានាឱ្យបុរសមានវត្តមានក្នុងកិច្ចប្រជុំស្តីពីអនាម័យ គឺជាការលំបាក។ បុគ្គលិកធ្វើការក្នុងកម្មវិធីលើកកម្ពស់អនាម័យជនបទ នៅកម្ពុជា (CRSHIP) ច្រើនសង្កេតឃើញភាពខុសគ្នាទៅតាមភេទ ក្នុងការចូលរួមក្នុងសកម្មភាពបំផុសកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង។ អ្នកចូលរួមភាគច្រើន គឺជាស្ត្រី។ នៅប្រទេសអាហ្វហ្គានីស្ថាន បុរស និងក្មេងប្រុសចូលរួមក្នុងដំណើរការសហគមន៍ដឹកនាំអនាម័យទាំងស្រុងនៅទីសាធារណៈ ខណៈពេលអ្នកសម្របសម្រួលជាស្ត្រី ទៅតាមជួបជាមួយស្ត្រីតាមលំនៅស្ថាន។ កិច្ចប្រជុំបំផុសនៅប្រទេសអង់ហ្គោឡាភាគខាងត្បូង និងតំបន់ Caprivi នៃប្រទេសណាមីប៊ី មានស្ត្រីចូលរួមច្រើន ដោយសារបុរសជាច្រើនបានចេញទៅធ្វើជាពលករចំណាកស្រុក (Kidd, pers.comm.)។ សម្រាប់កម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងនៅឯប្រជុំកោះសូឡូម៉ុន ក៏មានចំនួនស្ត្រីចូលរួមក្នុងកិច្ចប្រជុំបំផុសច្រើនជាងបុរសដែរ (ឯកសារយោងដូចខាងលើ)។

## ការប្រើប្រាស់បង្គន់ជាប្រចាំរបស់បុរស

មានការព្រួយបារម្ភថា បុរសទំនងជាមិនប្រើបង្គន់សម្រាប់ការបន្ទោរបង់គ្រប់ពេលមិនថាពេលនៅផ្ទះ ឬចេញក្រៅនោះទេ។ ការសិក្សាមួយនៅរដ្ឋ Uttar Pradesh បង្ហាញថា

ទោះបីជាគ្រួសារមានបង្គន់ដែលដំណើរល្អក្តី ក៏បុរសទំនងជាមិនមែនជាអ្នកប្រើប្រាស់ជាប្រចាំដែរ (WSP 2016)។ ហេតុផលផ្សេងៗដែលបានដកស្រង់មករួមមាន ដើម្បីកាត់បន្ថយល្បឿនរណ្តៅបង្គន់ បុរសមានពេលច្រើនសម្រាប់ការបន្ទោរបង់ពាសវាលពាសកាល បុរសអាចដើរហើរបានច្រើន មិនសូវមានអារម្មណ៍ខ្មាសអៀនចំពោះការបន្ទោរបង់ពាសវាលពាសកាល គ្មានបង្គន់នៅកន្លែងធ្វើការ ការត្រឡប់ទៅរកការបន្ទោរបង់ពាសវាលពាសកាលវិញនៅពេលបង្គន់គ្រួសារមានអ្នកប្រើប្រាស់ច្រើន (Coffey et al. 2014; Chambers and Myers 2016)។ បុរសមិនសូវមានការព្រួយបារម្ភពីសន្តិសុខ/សុវត្ថិភាពនៅពេលបន្ទោរបង់ពាសវាលពាសកាល ដូចស្ត្រីនោះទេ។ ជាងនេះទៅទៀត ប្រទេសជាច្រើនមានបទដ្ឋានវប្បធម៌តឹងរ៉ឹងពាក់ព័ន្ធការប្រើប្រាស់បង្គន់រួមគ្នារវាងបុរស និងស្ត្រី។ នៅ ៖

- ប្រទេសបង់ក្លាដេស បុរសបន្ទោរបង់ក្នុងគុម្ពោតព្រៃ ដើម្បីជៀសវាងការប្រើប្រាស់បង្គន់រួមជាមួយកូនប្រសារស្រី (Hanchette et al. 2011)។
- សហគមន៍ Idoma ក្នុងប្រទេសនីហ្សេរីយ៉ា ប្តីបដិសេធមិនប្រើបង្គន់រួមជាមួយប្រពន្ធ និងកូនស្រី (WaterAid 2009)។
- ប្រទេសហ្វ្រាំប៊ីភាគខាងកើត បុរសជាមេគ្រួសារមិនប្រើបង្គន់រួមជាមួយសមាជិកគ្រួសារទេ ប្រសិនបើមានហានិភ័យពីការមើលឃើញពីអ្នកដទៃ (Thys et al. 2015)។
- ប្រទេសអេត្យូពី ការមើលឃើញលាមករបស់ស្ត្រីគឺជាការទទួលយកមិនបានហើយ បុរសនឹងបន្ទោរបង់ពាសវាលពាសកាលដើម្បីបញ្ចៀសចំណុចនេះ (Ashebir et al. 2013)។
- ប្រទេសម៉ាដាកាស្កា បុរស (ឬក្មេងប្រុស) មិនអាចបន្ទោរបង់ក្នុងកន្លែងតែមួយជានឹងស្ត្រីបានទេ (រួមទាំងបងប្អូនស្រីរបស់ពួកគេ) (UNICEF 2015a)។
- ប្រទេសនេប៉ាល់ បុរសចំណាស់អាចនឹងបដិសេធមិនប្រើប្រាស់បង្គន់ (សូម្បីតែជាបង្គន់ផ្ទាល់ខ្លួន) ដែលកូនប្រសារស្រីធ្លាប់បានប្រើ ដូច្នេះហើយពួកគាត់នឹងបន្ទោរបង់ពាសវាលពាសកាល (SNV 2017)។
- ប្រទេសស៊ូដង់ខាងត្បូង មានជំនឿថា សាច់ថ្លៃមិនអាចបន្ទោរបង់ក្នុងបង្គន់តែមួយបានទេ។ អ្នកខ្លះក៏មានជឿថា ប្រសិនបើស្ត្រីប្រើបង្គន់ ពួកគេនឹងមិនអាចមានកូន (Kidd, pers.comm)។
- ក្នុងស្រុក Phalombe ភាគខាងត្បូងនៃប្រទេសម៉ាឡាវី បុរសដែលប្រើបង្គន់រួមគ្នាជាមួយនឹងម្តាយក្មេក (ឬស្ត្រីប្រើប្រាស់បង្គន់រួមគ្នាជាមួយនឹងឪពុកក្មេក) គឺជាឥរិយាបថដែលមិនអាចទទួលយកបានសម្រាប់វប្បធម៌របស់គេ។ នៅទីនេះ បុរសមានអារម្មណ៍ផាសុខភាពជាងក្នុងការបន្ទោរបង់ក្នុងគុម្ពោតព្រៃ ហើយមិនសូវចង់ប្រើប្រាស់បង្គន់។ បុរសមិនយល់ថាបង្គន់ជាផ្នែកមួយនៃការរស់រានជាមូលដ្ឋានឡើយ (Kidd, pers.comm.)។

## ការបត់ជើងតូចពាសវាលពាសកាលដោយបុរស

ការបត់ជើងតូចពាសវាលពាសកាលដោយបុរស ជាការអនុវត្តទូទៅនៅជុំវិញពិភពលោក ទោះបីជាសកម្មភាពនេះអាចបង្កប៉ះពាល់ដល់ភាពសមរម្យក្នុងទីសាធារណៈ ហើយច្រើនតែត្រូវបានហាមឃាត់ដោយលក្ខន្តិកៈ និងអាចប្រឈមនឹងទណ្ឌកម្ម ជាប្រាក់ពិន័យ និង/ឬសេវាសហគមន៍ក្តី។ នៅប្រទេសឥណ្ឌា ការបត់ជើងតូចពាសវាលពាសកាលត្រូវបានដាក់បញ្ចូលក្រោមបេសកកម្ម Swachh Bharat (បេសកកម្មឥណ្ឌាស្អាត) ដើម្បីបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលត្រឹមថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១៩។ Thokne (2016) និង Upadhayaya (2015) លើកឡើងថា ទីក្រុងញូដេលី បានធ្វើយុទ្ធនាការលើកកំពស់ការយល់ដឹងជាសាធារណៈតាមរយៈការបិទបង្ហាញលើក្តារប្រកាសព័ត៌មានដែលសរសេរថា "តើអ្នកនៅតែគ្មានការទទួលខុសត្រូវរហូតដល់ពេលណា? យ៉ាងហោចណាស់ ក៏គួរតែមានការអៀនខ្មាសខ្លះ។ សូមលាងជម្រះផ្នត់គំនិតរបស់អ្នកឱ្យស្អាត"។ រូបភាពអាទេព ទេពធីតា និងគ្រឿងសម្គាល់សក្តិសិទ្ធ ឬអត្ថបទដកស្រង់ចេញពីគម្ពីរកូរ៉ាន ត្រូវបានគូសលើជញ្ជាំងដើម្បីកុំឱ្យបុរសបត់ជើងតូចនៅទីនោះ។

## ការលាងសម្អាតដៃជាមួយសាប៊ូ ដោយបុរសនៅពេលវេលាចាំបាច់

នៅជុំវិញពិភពលោក មានការបង្ហាញថា បុរសទំនងជាមិនសូវលាងសម្អាតដៃជាមួយសាប៊ូតាមពេលវេលាសំខាន់ៗឱ្យបានជាប្រចាំឡើយ។ នៅប្រជុំកោះសូឡូម៉ុន និងប្រទេសផ្សេងទៀត បុរសរំពឹងថា ស្ត្រីគួរទទួលខុសត្រូវលើការបង្រៀនកូនឱ្យអនុវត្តការលាងសម្អាតដៃជាប្រចាំ។ ចំណុចនេះត្រូវបានកំណត់ថាជាទំនៀមទំលាប់/វប្បធម៌ (kastom) ដែលម្តាយគឺជាអ្នករ៉ាប់រងគ្រប់សកម្មភាពក្នុងគ្រួសារទាំងអស់។ ក្នុងកិច្ចពិភាក្សាក្រុមគោលដៅមួយស្តីពីការលាងសម្អាតដៃ ស្ត្រីម្នាក់និយាយថា *"ខ្ញុំជំរុញឱ្យប្តី និងកូនៗរបស់ខ្ញុំលាងសម្អាតដៃនៅពេលពួកគេត្រឡប់ពីបង្គន់។ ខ្ញុំប្រាប់ពួកគេថា 'លាងដៃរបស់អ្នក'។ ប្តីខ្ញុំខ្ជិលលាងដៃ។ គាត់មិនទម្លាប់លាងសម្អាតដៃទេ។ ខ្ញុំជាបុគ្គលតែម្នាក់គត់ដែលលាងសម្អាតដៃក្នុងគ្រួសារ។ ប៉ុន្តែប្តីខ្ញុំចំអកឱ្យខ្ញុំថា "តើអូនចង់រស់នៅដូចស្ត្រីស្បែកសមែនទេ?"* (Kidd, pers. comms., March 2018)។ កិច្ចខិតខំប្រឹងប្រែងក្នុងលើកកម្ពស់ការលាងសម្អាតដៃដែលផ្តោតលើឥរិយាបថ និងការអនុវត្តរបស់បុរស អាចជួយបំផុសការផ្លាស់ប្តូរទម្លាប់លាងសម្អាតដៃ (Maulit 2015)។ ឧ. បច្ចេកទេស "ការបន្ទោរបង់ និងការចាប់ដៃ" ដែលបង្កើតឡើងដោយ Engineers without Borders នៅប្រទេសម៉ាឡាវីផ្តោតលើការអនុវត្តរបស់បុរស និងផ្សារភ្ជាប់បុរសទៅនឹងការផ្លាស់ប្តូរឥរិយាបថអនាម័យ។

## ភាពជាដៃគូរបស់បុរសក្នុងដំណើរការអនាម័យសហគមន៍

មានឯកសារជាច្រើនស្តីពីការចូលរួមរបស់បុរសក្នុងដំណើរការទឹកស្អាត និងអនាម័យ ប៉ុន្តែមិនសូវមានឯកសារស្តីពីរបៀបដែលបុរសអាចសហការជាមួយស្ត្រី ដើម្បីគាំទ្រឱ្យពួកគេចូលរួមក្នុងដំណើរការអនាម័យសហគមន៍ឡើយ។ ប្រសិនបើបុរសមិនត្រូវបាន

ជំរុញឱ្យចូលរួម ក្នុងការសម្របសម្រួលឱកាសឲ្យស្ត្រីចូលរួមធ្វើសេចក្តីសម្រេចចិត្តក្នុងដំណើរការទឹកស្អាត និងអនាម័យទេ កម្មវិធីអនាម័យនោះអាចនឹងធ្វើឱ្យស្ត្រីរ៉ាប់រងបន្ទុកថែទាំកាន់តែច្រើន។ ការសម្របសម្រួលភាពជាដៃគូរបស់បុរសដើម្បីគាំទ្រដល់ស្ត្រីក្នុងដំណើរការទឹកស្អាត និងអនាម័យជាផ្នែកថ្មីមួយក្នុងវិស័យទឹកស្អាត និងអនាម័យ (ឧ. ការសិក្សាពីសហគ្រិនជាស្ត្រី)។

## បុរសបំពេញតួនាទីថែទាំក្នុងគ្រួសារ

កិច្ចការថែទាំ និងកិច្ចការផ្ទះបានក្លាយជាបន្ទុកដ៏ធំរបស់ស្ត្រីពីគ្រប់វប្បធម៌ទាំងអស់ ប៉ុន្តែកម្រិតវិសមភាពគឺមានភាពខុសគ្នា។ មានការផ្តោតយ៉ាងច្រើនលើតួនាទីថែទាំក្នុងកិច្ចការអភិវឌ្ឍន៍ជាច្រើន ប៉ុន្តែមិនសូវផ្តោតក្នុងវិស័យអនាម័យនោះទេ។ ស្ត្រីជារឿយៗត្រូវបានប្រគល់ទំនួលខុសត្រូវអនាម័យក្នុងគ្រួសារឲ្យ ដូចជា ការដងទឹកសម្រាប់លាងសម្អាតដៃ ការយកកូនទៅលាងសម្អាតដៃ ការចាក់ទឹកបំពេញធុងទឹកលាងការទុកដាក់ទឹកដោយសុវត្ថិភាព ការលាងចាន ការសម្អាតបង្គន់។ល។ ការសម្អាតបង្គន់ សូម្បីតែបង្គន់ក្នុងសាលារៀន និងបង្គន់សាធារណៈ ជារឿយៗជាតួនាទីរបស់ស្ត្រី។ ការបែងចែកការងារអនាម័យដោយមិនស្មើភាព អាចពង្រឹងតួនាទីយេនឌ័រ និងធ្វើឱ្យស្ត្រីមានពេលវេលាតិចតួច និងរឹតត្បិតតួនាទី និងជម្រើសរបស់ស្ត្រីទាំងក្នុង និងក្រៅផ្ទះ។ ការផ្លាស់ប្តូរតួនាទីយេនឌ័រ ដែលបុរសមានការទទួលខុសត្រូវខ្លះលើការសម្អាតផ្ទះ បង្គន់ និងបរិស្ថានអាចជួយឱ្យស្ត្រី និងក្មេងស្រីបំពេញតួនាទី នឹងជម្រើសផ្សេងទៀតទាំងក្នុង និងក្រៅគ្រួសារ រួមទាំងការងារ និងការសិក្សា។

## ផ្តត់គំនិតសង្គមក្នុងដំណើរការសហគមន៍ដឹកនាំអនាម័យទាំងស្រុង

បញ្ហាអំណាចយេនឌ័រ មានទាំងនៅក្នុងរបៀបគ្រប់គ្រងអនាម័យក្នុងគ្រួសារនោះទេ និងទាំងក្នុងអន្តរាគមន៍ និងកម្មវិធីសហគមន៍។ នៅប្រទេសហ្ស៊ីមបាវ៉េ អ្នកសម្របសម្រួលសហគមន៍ម្នាក់បានលើកឡើងប្រាប់បុរសៗមួយចំនួនថា គាត់ស្គាល់កំប៉េះគូទប្រពន្ធរបស់ពួកគេ។ បុរសទាំងនោះខឹងសម្បារ និងភ្ញាក់ផ្អើលជាខ្លាំង រួចសួរថា "ម៉េចនឹងអាចទៅរួច?"។ អ្នកសម្របសម្រួលនោះពន្យល់ថា គាត់បានឃើញកំប៉េះគូទរបស់ស្ត្រីទាំងនោះនៅពេលពួកគាត់សើយរ៉ូបបន្ទោរបង់ក្នុងគុម្ពោតព្រៃ។ បុរសទាំងនោះយល់ និងយល់ព្រមសង់បង្គន់ក្នុងផ្ទះរបស់ខ្លួន (Charuka, n.d.)។ ការទាញប្រយោជន៍ពីឧត្តមគតិនៃការការពារបែបបិតាធិបតេយ្យក្នុងចំណោមបុរស ធ្វើឱ្យពួកគេអាចសងបង្គន់បាន ប៉ុន្តែលទ្ធផលទទួលបាន គឺការពង្រឹងឧត្តមគតិបិតាធិបតេយ្យនៃការគ្រប់គ្រងលើស្ត្រី ជាចំណុចដែលផ្ទុយទាំងស្រុងនឹងកត្តាចាំបាច់សម្រាប់ឱ្យស្ត្រីចូលរួមប្រកបដោយអត្ថន័យ ឬដើរតួនាទីដឹកនាំ។ លើសពីនេះ សៀវភៅព័ត៌មានស្តីពីសហគមន៍ដឹកនាំអនាម័យទាំងស្រុង បានកត់សម្គាល់ពីភាពខុសគ្នារវាងការដឹកនាំរបស់បុរស និងស្ត្រី ៖ "ស្ត្រីដែលមានទេពកោសល្យជាអ្នកដឹកនាំពីធម្មជាតិ ហាក់មិនសូវមានភាពលេចធ្លោរដូចបុរស ពាក់ព័ន្ធនឹងការសង់បង្គន់ទេ ប៉ុន្តែពួកគេមានភាពសកម្មភាព និងការទទួលខុសត្រូវច្រើនជាងបុរសក្នុងការជួសជុលថែទាំ ការបង្កើតបទដ្ឋាននៃការប្រើប្រាស់ និងការធានាការផ្លាស់ប្តូរ

ឥរិយាបថដែលមានអនាម័យ" (Kar with Chambers 2008: 48)។ ក្នុងស្រុក Bombali ប្រទេសសេរ៉ាឡេអូន គេប៉ាន់ស្មានថា ស្ត្រីមានសមាសភាគប្រមាណ ៣០%-៤០% ក្នុងសមាជិកគណៈកម្មាធិការអនាម័យ និងក្នុងចំណោមអ្នកមានទេពកោសល្យដឹកនាំពីធម្មជាតិ (Kidd, pers. comm.)។ ក្នុងកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងនៅប្រជុំកោះសូឡូម៉ុន អ្នកដឹកនាំជាបុរស បានជ្រើសរើសបុរសជាច្រើនធ្វើជាតំណាងភូមិ នៅក្នុងកម្មវិធីបណ្តុះបណ្តាលអ្នកសម្របសម្រួលសហគមន៍ ដឹកនាំអនាម័យទាំងស្រុង (Kidd, pers. comm.)។ បុរសអាចអនុវត្តគំនិតផ្តួចផ្តើមកាន់តែច្រើនដើម្បីជំរុញការចូលរួម សកម្មរបស់ស្ត្រីក្នុងការធ្វើសេចក្តីសម្រេចចិត្ត ពាក់ព័ន្ធនឹងទឹកស្អាត និងអនាម័យ ដោយយកលំនាំនៃការអនុវត្តន៍ដែលនឹងរៀបរាប់ក្នុងផ្នែកបន្ទាប់ទៀតនៃឯកសារនេះ។

## បុរស និងក្មេងប្រុស

បុរសខុសគ្នាដោយសារវណ្ណៈ ត្រកូល ក្រុមសង្គម ផ្លូវភេទ ពិការភាព ជាតិពន្ធុ អាយុ ជាមួយនឹងតម្រូវការអនាម័យខុសគ្នាទៅតាមដំណាក់កាលផ្សេងៗនៃជីវិត ដែលកិច្ចខិតខំប្រឹងប្រែងពង្រឹងអនាម័យអាច និងត្រូវតែដោះស្រាយ៖

- **ក្មេងប្រុស៖** នៅសាលារៀន ក្មេងប្រុស និងក្មេងស្រី រៀនពីកិច្ចការដែល "សមស្រប" សម្រាប់យេនឌ័ររបស់ខ្លួន។ ការដាក់បញ្ចូលបញ្ហាអនាម័យគ្រួសារទៅក្នុងកម្មវិធីសិក្សាស្តីពី "បំណិនជីវិត" អាចគាំទ្រឱ្យមានការផ្លាស់ប្តូរ។ មានការបង្កើតល្បែងកំសាន្តផ្អែកលើសកម្មភាពទឹកស្អាត និងអនាម័យដូចជា ល្បែងពស់ និងជណ្តើរដោយ WaterAid ទីម័រខាងកើត និងដោយ Street Football World Network និង WASH United ដើម្បីជួយឱ្យក្មេងប្រុសរៀនពីឥរិយាបថទឹកស្អាត និងអនាម័យក្នុងការហ្វឹកហាត់កីឡា ជាប្រចាំរបស់ខ្លួន។ អង្គការទស្សនៈពិភពលោក និង Sesame Workshop បានសហការគ្នារៀបចំកម្មវិធី WASHUP! ដែលជាកម្មវិធីផ្លាស់ប្តូរឥរិយាបថអនាម័យតាមសាលារៀន និងកំពុងត្រូវបានអនុវត្តក្នុងប្រទេសចំនួន ១១។ កម្មវិធីនេះផ្តោតលើឥរិយាបថអនាម័យសមស្របក្នុងចំណោមសិស្សទាំងអស់ និងការប្រើប្រាស់តួអង្គស្ត្រីដ៏រឹងមាំ (Raya)។ នាងជាបុគ្គលដឹកនាំគំរូក្នុងការជួយដល់មិត្តភក្តិប្រុសរបស់នាង (Elmo) ឱ្យយល់ និងប្រកាន់ខ្ជាប់ឥរិយាបថអនាម័យសមស្រប។

- **មនុស្សវ័យជំទង់៖** សៀវភៅស្តីពីការពេញវ័យ ត្រូវបានចងក្រងឡើងសម្រាប់ក្មេងប្រុសអាយុ ១០-១៤ ឆ្នាំក្នុងប្រទេសតង់ហ្សានី។ សៀវភៅនេះមានការណែនាំស្តីពីការប្រែប្រួលរាងកាយរបស់ក្មេងប្រុស និងចលនាយេនឌ័រដែលនាំមកនូវសុខភាពល្អ ដោយផ្អែកលើការស្រាវជ្រាវដែលចូលរួមដោយក្មេងប្រុសជំទង់។ ក្រុមប្រឹក្សាកិច្ចសហការផ្គត់ផ្គង់ទឹក និងអនាម័យ (WSSCC) បានចងក្រងកូនសៀវភៅបត់ដែលណែនាំពីការប្រែប្រួលរាងកាយរបស់ក្មេងប្រុស និងក្មេងស្រី និងវិធីល្អបំផុតក្នុងការណែនាំពីប្រធានបទនេះ (សូមមើលរូបភាពខាងក្រោម ៖ "នៅពេលយើងចម្រើនវ័យ")។




'As We Grow Up'. *Credit: WSSCC 2013.*

- **បុរស៖** តម្រូវការអនាម័យរបស់បុរសអាចកំណត់ដោយតួនាទីរបស់បុរសក្នុងគ្រួសារ និងកន្លែងធ្វើការ។ ជាទូទៅ បុរសជាអ្នកផ្តល់បង្គន់ និងជាអ្នកការពារសុខភាព និងអនាម័យរបស់គ្រួសារ និង "សេចក្តីថ្លៃថ្នូរ និង "ភាពឯកជន" របស់ស្ត្រី។

- **បុរសចំណាស់៖** បុរសចំណាស់ច្រើនតែមានតម្រូវការអនាម័យដែលពិបាកបំពេញក្នុងបរិបទមួយចំនួន ដូចជា ពាក់ព័ន្ធនឹងភាពមិនអំណត់ ឬត្រូវបត់ជើងតូចញឹកញាប់។ នៅខែ វិច្ឆិកា ឆ្នាំ ២០១៤ ក្នុងជំរំ Zaatari ក្នុងប្រទេសហ្ស៊កដានី ខោទឹកនោមសម្រាប់មនុស្សពេញវ័យមានតម្លៃថ្លៃ និង/ឬរកទិញបានមិន ហើយគ្រួសារមួយដែលផ្គត់ផ្គង់ បុរសចំណាស់ម្នាក់ដែលគ្មានភាពអំណត់ ត្រូវបង្ខំចិត្តច្នៃខោនោមដោយប្រើកន្ទបចាស់ៗ និងថង់ប្លាស្ទិក (Venema 2015)។

កម្មវិធីទឹកស្អាត និងអនាម័យកំពុងអនុវត្តវិធីសាស្ត្របែបប្រទាក់ក្រឡា ដែលអាចជាវិធីមួយក្នុងការផ្សារភ្ជាប់វិសមភាពយេនឌ័រទៅនឹងវិសមភាពសង្គម។ ការស្វែងយល់ពីភាពខុសគ្នាទៅតាមវណ្ណៈ ត្រកូល អាយុ សាសនា ជាតិពន្ធុ ផ្លូវភេទ និងកម្រិតប្រាក់ចំណូល តាមរយៈឧបករណ៍ពិនិត្យតាមដានបែបចូលរួម ដូចជា ឧបករណ៍ពិនិត្យតាមដានទឹកស្អាត និងអនាម័យ និងយេនឌ័ររបស់អង្គការភ្លែនអន្តរជាតិ (២០១៤) បានជំរុញការផ្តោតជាសំខាន់លើក្រុមបុរស និងក្មេងប្រុសមួយចំនួន (និងស្ត្រី និងក្មេងស្រី) ឱ្យកាន់តែមានប្រសិទ្ធភាពពាក់ព័ន្ធនឹងអនាម័យ។

**ផ្នែកខាងក្រោមពិនិត្យឡើងវិញលើតួនាទីខុសគ្នារបស់បុរស និងក្មេងប្រុស ក្នុងនាមជាកម្មវត្ថុនៃការផ្លាស់ប្តូរ ភ្នាក់ងារនៃការផ្លាស់ប្តូរ និងដៃគូនៃការផ្លាស់ប្តូរក្នុងដំណើរការអនាម័យ។**

## ១.បុរសក្នុងនាមជាអ្នកជំទាស់ការផ្លាស់ប្តូរ

ក្នុងបរិបទមួយចំនួន គេសង្កេតឃើញថា បុរសជំទាស់នឹងការផ្លាស់ប្តូរ ដែលត្រូវបាន

លើកកម្ពស់ក្នុងកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង ដំណើរការលើកកម្ពស់ការលាងសម្អាតដៃបែបចូលរួម ឬទីផ្សារអនាម័យ។ ជាញឹកញាប់ បុរស និងក្មេងប្រុសត្រូវបានចាត់ទុកជាឧបសគ្គដល់ការសម្រេចបានសហគមន៍ ដែលគ្មានការបន្ទោរបង់ពាស់វាលពាសកាល និងជាកម្មវត្ថុដែលត្រូវផ្លាស់ប្តូរដើម្បីសម្រេចគោលបំណង "គ្មានការបន្ទោរបង់ពាសវាលពាសកាល"។ ពាក្យ "កម្មវត្ថុ" នៅចំណុចនេះត្រូវបានប្រើប្រាស់ជាការទិតៀនក្នុងឯកសារមានស្រាប់ស្តីពីអនាម័យ ដែលសំដៅលើបុរស និងក្មេងប្រុស។

## ការរួមបញ្ចូលបុរស និងក្មេងប្រុសក្នុងដំណើរការអនាម័យ

ក្នុងប្រទេសមួយចំនួន មានការលើកឡើងពីការលំបាកក្នុងការជំរុញឱ្យបុរសចូលរួមក្នុងវគ្គបំផុសសហគមន៍ដឹកនាំអនាម័យទាំងស្រុង ឬធានាថា ពួកគេមានវត្តមានក្នុងព្រឹត្តិការណ៍នានា។ កម្មវិធីដែលមិនកំណត់ពេលវេលាបានល្អសម្រាប់ព្រឹត្តិការណ៍បំផុសហាក់មិនគ្របដណ្តប់លើចំណែកនានាក្នុងសហគមន៍។ Kar with Chambers (2008:17) កត់សម្គាល់ថា "ដោយសារមូលហេតុផ្សេងៗ បុរសដែលមកពីវណ្ណៈកណ្តាល/ខ្ពស់ និងសមាជិកសហគមន៍ដែលមានឥទ្ធិពល ប្រហែលជាមិនមានវត្តមានក្នុងការបំផុសនេះទេ។ អវត្តមានបុគ្គលគ្រប់ប្រភេទ អាចនឹងធ្វើឱ្យអំណាចជាសមូហភាពនៃ "ការធ្វើសេចក្តីសម្រេចចិត្តស្តីពី "ការបំផុស" ចុះខ្សោយ។ មានការសង្កេតឃើញថា បុរសមិនសូវចូលរួមក្នុងកិច្ចប្រជុំដើម្បីពិភាក្សាពីឥរិយាបថអនាម័យទេ។ ក្នុងប្រទេសទីម័រខាងកើត កិច្ចប្រជុំស្តីពីសហគមន៍ដឹកនាំអនាម័យទាំងស្រុងច្រើនតែរៀបចំឡើងនៅពេលល្ងាច ដើម្បីឱ្យបុរសងាយចូលរួម។ សកម្មភាពទីផ្សារអនាម័យផ្តោតសំខាន់លើទីកន្លែងដែលបុរសជួបជុំដូចជា ហាងតែក្នុងប្រទេសនេប៉ាល់ (Krukkert et al. 2010)។ ក្នុងប្រទេសបង់ក្លាដេស កម្មវិធី WASH+ ផ្តោតលើកន្លែងដែលបុរសជួបជុំច្រើន (ដូចជា ហាងតែ) ដើម្បីផ្សព្វផ្សាយពីសៀវភៅកាតាឡុកជម្រើសអនាម័យ[1] ។

អនាម័យអាចសន្មតជាអាទិភាពទាប ឬស្ថានភាពទាប។ អ្នកសម្របសម្រួលកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងបានប្រើប្រាស់វិធីសាស្ត្រថ្មីៗមួយចំនួនដើម្បីបញ្ចុះបញ្ចូលឱ្យបុរស (ជាពិសេសបុរសវ័យក្មេង) ចូលរួមក្នុងសកម្មភាពបំផុស។ ឧ. នៅពេលអ្នកសម្របសម្រួល ក្នុងគម្រោងលើកកម្ពស់អនាម័យជនបទ របស់មូលនិធិអនាម័យសកល (GSF) ក្នុងប្រទេសនីហ្សេរីយ៉ា (RUSHPIN) ចុះទៅសហគមន៍រងផលប៉ះពាល់ដោយសារជម្លោះក្នុងតំបន់ Abi យុវជនលើកឡើងថា សន្តិសុខគឺជាចំណុចអាទិភាព មិនមែនការសង់បង្គន់នោះទេ។ "នៅពេលយើងចាប់ផ្តើមការងារនេះ ការឆ្លើយតបដំបូងមានភាពយឺតយ៉ាវ ដោយសារតែយុវជនមិនទទួលយកគំនិតនេះ។ យុវជនភាគច្រើនមិនបានចូលរួមក្នុងព្រឹត្តិការណ៍ "បំផុស" ទេ ព្រោះពួកគេរវល់ប្រចាំការជាអ្នកឃ្លាំមើលក្នុងគុម្ពោតព្រៃ (Ekhator and England 2015)។

[1] http://www.washplus.org/sites/default/files/resource_files/clts_brief2015.pdf

ក្នុងប្រទេសសេរ៉ាឡេអូន និងទីម័រខាងកើត អ្នកសម្របសម្រួលកម្មវិធី បានខិតខំជំរុញការចូលរួមរបស់យុវជនក្នុងការជីករណ្តៅបង្គន់ និងសង់បង្គន់។ យុវជនទាំងនោះជាសមាជិកក្រុមយុវជនក្នុងមូលដ្ឋាន និងដើរជាក្រុមជុំវិញភូមិដើម្បីជីករណ្តៅបង្គន់ឱ្យគ្រួសារងាយរងគ្រោះ។ នេះជាការរួមចំណែករបស់ពួកគេក្នុងការជំរុញស្ថានភាព "គ្មានការបន្ទោរបង់ពាសវាលពាសកាល"។

*នៅពេលដែលហ្វីលីព និងជូលី (តួអង្គពីរនាក់ដែលមានទេពកោសល្យជាអ្នកដឹកនាំពីកំណើត) បានស្នើឱ្យអ្នកភូមិទាំងអស់ចំណាយពេលពេញមួយថ្ងៃដើម្បីសង់បង្គន់ ពួកគេសង្កត់ធ្ងន់ថា "នេះមិនមែនជាថ្ងៃដែលយើងមកនិយាយគ្នា ឬប្រជុំជាមួយគ្នាទេប៉ុន្តែវាជាថ្ងៃធ្វើការ ពោលគឺជាថ្ងៃដែលត្រូវធ្វើកិច្ចការជីកកាយ និងសង់បង្គន់។ ដូច្នេះ កិច្ចការរបស់អ្នកដែលមានទេពកោសល្យជាអ្នកដឹកនាំពីកំណើតក្នុងការជួយសង់បង្គន់ ទាមទារនូវយុវជនដែលមានកម្លាំងខ្លាំងក្លា (Kidd. Pers. comms.)។*

បុរសក្នុងសហគមន៍គង្វាលសត្វ ក៏អាចជាក្រុមដែលពិបាកចូលដល់ផងដែរ។ កម្មវិធីលើកកម្ពស់អនាម័យក្នុងប្រទេសកេនយ៉ា (K-SHIP) ដែលទទួលបានជំនួយពីមូលនិធិអនាម័យសកល តាមរយៈ Amref Health Africa បានគោលបំណងផ្សព្វផ្សាយដល់បុរសជនជាតិ Maasai។ ការបញ្ចុះបញ្ចូលឱ្យបុរសចូលរួមក្នុងកិច្ចប្រជុំស្តីពីអនាម័យគឺជាការលំបាក ព្រោះពួកគេច្រើនតែចេញបាត់ពីផ្ទះទៅដងទឹក និងឃ្វាលសត្វ។ ដូច្នេះហើយទើបមានគំនិតផ្តល់ពពែដុត (olpul) នៅពេលបំផុសដើម្បីជំរុញការចូលរួមរបស់បុរសទាំងនោះ។ ឧទាហរណ៍ នេះគូសបញ្ជាក់ពីបញ្ហាប្រឈមក្នុងការជំរុញការចូលរួមរបស់បុរសតាមរបៀបដែលមិនពង្រឹងវិសមភាពអំណាច និងផ្តល់បុព្វសិទ្ធិបិតាធិបតេយ្យថ្មី ឬបន្ថែមសម្រាប់បុរស ដែលស្ត្រីត្រូវបានផាត់ចេញ (ស្ត្រីមិនអាចញ៉ាំចៀមដុតបានទេ)។

ក្នុងប្រទេសនេប៉ាល់ Krukkert et al. (2010) លើកឡើងថា បុរសមិនងាយចូលរួមសកម្មភាពលើកកម្ពស់អនាម័យទេ ប្រសិនបើពួកគេគ្រាន់តែជាអ្នកស្តាប់"។ ពួកគេនឹងចូលរួមសកម្មភាពលើកកម្ពស់អនាម័យ ប្រសិនបើមានការផ្តល់តួនាទីជាក់លាក់ដល់ពួកគេ។ អ្នកនិពន្ធលើកឡើងពីតួនាទីចែករំលែកព័ត៌មាន ឬតួនាទីដឹកនាំមួយចំនួនជាមួយស្ត្រី។ ដូចគ្នានឹងឧទាហរណ៍មុនៗស្តីពីទំនោរនៃការជំរុញការចូលរួមរបស់បុរសតាមរយៈការធ្វើឱ្យពួកគេក្លាយជាអ្នកដែលមានទេពកោសល្យជាអ្នកដឹកនាំពីកំណើត ការលើកឡើងនេះគូសបញ្ជាក់ពីការលំបាកក្នុងការជំរុញការចូលរួមរបស់បុរស តាមរបៀបដែលមិនពង្រឹងវិសមភាពអំណាច។




យុទ្ធនាការអនាម័យ៖ បុរសអង្គុយខាងក្រោមសញ្ញាដែលសរសេរថា "ដើម្បីសម្អាតព្រលឹងរបស់អ្នក អ្នកត្រូវការព្រះវិហារ ដើម្បីសម្អាតរាងកាយរបស់អ្នក អ្នកត្រូវការបង្គន់" ក្នុងភូមិ Rajpara Bhayati ប្លុក Vallabhipur ឆ្នាំ ២០០៨។ ក្រេឌីត ៖ UNICEF/Adam Ferguson។

## យុទ្ធនាការ និងវិធីសាស្ត្រនានាដែលផ្តោតសំខាន់លើការផ្លាស់ប្តូរឥរិយាបថអនាម័យរបស់បុរស និងក្មេងប្រុស

ក្រុមហ៊ុន Uniliver បានបង្កើតសារតាតួអង្គ ដើម្បីផ្តោតលើការផ្លាស់ប្តូរឥរិយាបថរបស់បុរសក្នុងប្រទេសឥណ្ឌា។ តួអង្គ "បុរសល្អ" និង "បុរសរឹងមាំ" មានគោលបំណងផ្តោតលើ/ធ្វើទីផ្សារអនាម័យកាន់តែប្រសើរចំពោះបុរសទាំងនេះ។ ខាងក្រោមនេះជាការដកស្រង់ខ្លឹមសារក្នុងយុទ្ធនាការផ្ទាំងបដានេះ (Uniliver 2010) ៖

**អ្វីដែលបុរសរឹងមាំធ្វើ....**

*ខ្ញុំចេញទៅបន្ទោរបង់ក្រៅផ្ទះ ដូចបុរសខ្លាំងផ្សេងទៀតដែរ ព្រោះបង្គន់គឺសម្រាប់ស្ត្រី អ្នកឈឺ និងមនុស្សចាស់។*

**សូមធ្វើជាបុរសរឹងមាំ! សូមប្រើបង្គន់ដែលស្អាតគ្មានមេរោគ?**

**បុរសល្អ....**

*គ្រួសារ និងសហគមន៍នីមួយៗ សុទ្ធតែមានអ្នកដែលត្រូវការការមើលថែ៖ វាជាភារកិច្ចរបស់បុរស ដូចជារូបខ្ញុំដែលត្រូវធ្វើកិច្ចការនេះ។*

**តើយើងអាចអន្ទងឱ្យឪពុក "ធ្វើរឿងត្រឹមត្រូវ" ដើម្បីឱ្យគាត់ តម្រូវឱ្យសមាជិកគ្រួសាររបស់គាត់ទាំងអស់ (រួមទាំងរូបគាត់ផ្ទាល់) ប្រើប្រាស់បង្គន់គ្រប់ពេលដោយរបៀបណា?**

ខណៈដែលឃ្លាទាំងនេះត្រូវបានយកជាសំអាង និងប្រើប្រាស់សម្រាប់ "ការទាក់ទាញ" ដ៏សំខាន់សម្រាប់បុរសមួយចំនួន ការទាញប្រយោជន៍ពីផ្នត់គំនិត "បុរសរឹងមាំ"ត្រូវបានប្រើប្រាស់សម្រាប់ការពង្រឹងផ្នត់គំនិតដែលគ្មានប្រយោជន៍(និងឧត្តមភាពរបស់បុរស)។

យុទ្ធនាការផ្សេងទៀត ដែលទាមទារឱ្យបុរសផ្តល់បង្គន់ដល់គ្រួសាររបស់ខ្លួន មានគោលបំណងធ្វើឱ្យពួកគាត់មានអារម្មណ៍ "ដូចបុរសម្នាក់" (ឧ. យុទ្ធនាការគ្មានបង្គន់ គ្មានកូនក្រមុំនៅប្រទេសឥណ្ឌា និងយុទ្ធនាការស្រដៀងគ្នាក្នុងប្រទេសនេប៉ាល់, Krukkert et al. 2010)។ យុទ្ធនាការទាំងនេះលើកឡើងថា តួនាទីរបស់បុរសគឺជាអ្នកការពារសុខភាពរបស់គ្រួសារ និងភាពឯកជន និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី។ ឧ. បេសកកម្ម Swachh Bharat ត្រូវបានប្រើប្រាស់សម្រាប់ការពង្រឹងជាប្រព័ន្ធនូវអំណាចគ្របដណ្តប់របស់បុរសក្នុងការផ្តល់បង្គន់[2] ។ នៅតំបន់ Sepik ភាគខាងកើតក្នុងប្រទេសប៉ាពួញ៉ូហ្គីណេ WaterAid នឹង International Water Center, Divine World University និងដៃគូមូលដ្ឋានបានបង្កើតយុទ្ធនាការរយៈពេល ៤ សប្តាហ៍ (5-star mama em tru pla mama) ស្តីពីឥរិយាបថគ្រប់គ្រងលាមករបស់ទារក។ ម្តាយ និងឪពុកក្នុងសហគមន៍ត្រូវបានជ្រើសរើសឱ្យធ្វើជាភ្នាក់ងារផ្លាស់ប្តូរ ដើម្បីផ្តល់ព័ត៌មានស្តីពីការអនុវត្តសមស្របក្នុងការគ្រប់គ្រងលាមកទារកដោយសុវត្ថិភាព។ យោបល់ត្រឡប់ពីសហគមន៍បង្ហាញថា គម្រោងនេះបានលើកទឹកចិត្តឱ្យបុរសមួយចំនួនបំពេញកិច្ចការបន្ថែមទៀត ពាក់ព័ន្ធនឹងការមើលថែកូន ប៉ុន្តែមានការរិះគន់ថា យុទ្ធនាការនេះបានពង្រឹងតួនាទីរបស់ស្ត្រីក្នុងនាមជាអ្នកថែទាំបឋម (Kamundi and Pigolo 2018)។

## ការលាងសម្អាតដៃ

ការស្រាវជ្រាវជុំវិញពិភពលោកបង្ហាញថា បុរសមិនសូវលាងសម្អាតដៃដូចស្ត្រីទេ។ មានការធ្វើយុទ្ធនាការដែលផ្តោតលើបុរស ដើម្បីឱ្យពួកគេ លាងសម្អាតដៃជាមួយនឹងសាប៊ូ។ ឧ. កម្មវិធីលើកកម្ពស់អនាម័យជនបទនៅកម្ពុជា បានរៀបចំយុទ្ធនាការផ្ទាំងបដាក្រោមពាក្យស្លោក "បុរសភាគច្រើនមិនលាងសម្អាតដៃបន្ទាប់ពីប្រើបង្គន់រួច។ ចុះអ្នកវិញ?" នៅកម្ពុជា អង្គការ WaterAid Cambodia និងអង្គការ Epic Art បានផលិតវីដេអូតន្ត្រី "លាងសម្អាត" ដោយក្រុមសិល្បៈករពិការ រួមទាំងបុរស ដើម្បីរំលឹកឱ្យប្រជាជនលាងសម្អាតដៃជាមួយនឹងសាប៊ូនៅពេលវេលាសំខាន់ៗ ៖ https://www.youtube.com/watch?v=h Mc75WyaqZs។

### គម្រោងពង្រីកការលាងសម្អាតដៃជាសកល (WSP 2010)

ក្នុងប្រទេសសេណេហ្គាល់ ស្ត្រីគឺជាក្រុមគោលដៅនៃកិច្ចពិភាក្សាស្តីពីការលាងសម្អាតដៃ ដោយសារតែស្ត្រីដើរតួនាទីមើលថែយ៉ាងសំខាន់ក្នុងគ្រួសារ (សូមមើលផ្ទាំងបដាទីមួយខាងក្រោម)។ បុរសត្រូវបានរួមបញ្ចូលជាបន្តបន្ទាប់ (សូមមើលផ្ទាំងបដាទីពីរខាងក្រោម) បន្ទាប់ពីមានការទទួលស្គាល់ថា៖ ១) បុរសគ្រប់គ្រងលទ្ធភាព

[2] https://iapsdialogue.org/2017/05/03/making-india-open-defecation-free-at-the-cost-of-gender-equality/

របស់គ្រួសារ និងផ្គត់ផ្គង់ប្រាក់សម្រាប់ទិញសាប៊ូ ២) បុរសអាចតាមដានបន្តលើវគ្គផ្សព្វផ្សាយដើម្បីធានាថា សមាជិកគ្រួសាររបស់ខ្លួនលាងសម្អាតដៃជាមួយនឹងសាប៊ូ និង ៣) បុរសអាចផ្តល់លទ្ធភាព ពង្រឹង និងធានាការផ្លាស់ប្តូរឥរិយាបថតាមរយៈការលាងសម្អាតដៃរបស់ខ្លួនជាមួយនឹងសាប៊ូ ក៏ដូចជាជំរុញឱ្យអ្នកផ្សេងទៀតដូច្នេះដែរ។







*Credit: WSP, 2010*

## វិធីសាស្ត្រលើកទឹកចិត្តឱ្យបុរសបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល

មានយុទ្ធសាស្ត្រ និងវិធីផ្សេងទៀតដែលត្រូវបានប្រើប្រាស់ ដើម្បីលើកទឹកចិត្តឱ្យបុរសបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល។ តារាងខាងក្រោម លើកឡើងពីឧទាហរណ៍ក្នុងប្រទេសឥណ្ឌា។ ប៉ុន្តែភាគច្រើននៃការអនុវត្តទាំងនេះបានធ្វើឱ្យមានការព្រួយបារម្ភពីភាពមិនស៊ីសង្វាក់គ្នាជាក់ស្តែង ឬដែលអាចលេចឡើង ទៅនឹងសិទ្ធិមនុស្ស ហើយចំណុចនេះមិនអាចបណ្តែតបណ្តោយបានឡើយ (សម្រាប់ព័ត៌មានបន្ថែមសូមមើលឯកសារទី ៨ នៃកម្រងឯកសារ “ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង៖ សហគមន៍ដឹកនាំអនាម័យទាំងស្រុង និងសិទ្ធទទួលបានអនាម័យ”។

*ឧទាហរណ៍នៃការលើកទឹកចិត្តឱ្យបុរសបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលក្នុងប្រទេសឥណ្ឌា*

| | |
|---|---|
| Swachata Adalat៖ តុលាការអនាម័យ | តុលាការនេះបើកសវនាការរៀងរាល់ថ្ងៃ សៅរ៍ សម្រាប់អ្នកបន្ទោរបង់ពាសវាលពាសកាលដែលត្រូវបានចាប់ខ្លួនដោយសមាជិក nigrani samiti។ |
| ក្លឹបយុវជនក្នុងភូមិ Fazilpur Badli, Haryana | ក្លឹបយុវជនមានសមាសភាពបុរស និងស្ត្រីវ័យក្មេងដែលដើរតួនាទីដឹកនាំការបញ្ចុះបញ្ចូលឱ្យបុរសចំណាស់ប្រើបង្គន់។ |

| | |
|---|---|
| Nigrani samite, ភូមិ Kalarpur, Haryana | ស្ត្រីចំណាស់មួយក្រុម (និងបុរសចំណាស់មួយក្រុមផ្សេងទៀត) ដែលដូរវេនគ្នាឃ្លាំមើលអ្នកចេញបន្ទោរបង់ពាសវាលពាសកាលនៅពេលព្រឹក និងពេលល្ងាច។ ប្រសិនបើចាប់បានបុរសផ្សេងទៀតបន្ទោរបង់ពាសវាលពាសកាលក្នុងពេលព្រឹក ពួកគេនឹងទទូចឱ្យអ្នកបន្ទោរបង់នោះកាយដីលុបលាមក និងស្បថនៅចំពោះមុខសហគមន៍ថា ពួកគេនឹងមិនបន្ទោរបង់ពាសវាលពាសកាលទៀតទេ។ |
| ការពង្រឹងដោយ Gulabi Gang | Gulabi Gang ចុះតាមគ្រួសារដែលបន្ទោរបង់ពាសវាលពាសកាលជាប្រចាំ និងបញ្ចុះបញ្ចូលឱ្យបុរសប្រើប្រាស់បង្គន់ដើម្បីទទួលបានសុខភាពល្អ។ |
| Gandhigiri | សមាជិកគណៈកម្មាធិការ Nigrani ចុះតាមគ្រួសារដែលគ្មានបង្គន់ និងផ្តល់ម្សៅពណ៌ក្រហមសម្រាប់ការបន្ទោរបង់ពាសវាលពាសកាល និងផ្កាដល់សមាជិកគ្រួសារនោះ។ |
| ការបោះឆ្នោតអនាមិកជាសម្ងាត់ | នៅពេលគេសង្កេតឃើញនរណាម្នាក់បន្ទោរបង់ពាសវាលពាសកាល ឈ្មោះបុគ្គលនោះនឹងត្រូវបានសរសេរលើក្រដាស រួចយកទៅដាក់ក្នុងប្រអប់ឆ្នោត។ សមាជិក Panchayat និង nigrani samiti ជាអ្នកតាមដានបន្ត។ |

ប្រភព៖ Satyavada (នឹងបោះពុម្ពផ្សាយឆាប់ៗនេះ 2018)

ទោះបីជាស្ត្រីធ្វើកិច្ចការអនាម័យភាគច្រើនក្នុងគ្រួសារក្តី ប៉ុន្តែជាញឹកញាប់ បុរស (អ្នករកចំណូលផ្គត់ផ្គង់គ្រួសារ) ជាអ្នកសម្រេចចិត្តថាតើត្រូវវិនិយោគលើបរិក្ខារអនាម័យក្នុងផ្ទះ ប្រភេទបង្គន់ដែលត្រូវសង់ និងកន្លែងដែលត្រូវសង់បង្គន់។ ក្នុងបរិបទដែលបុរសធ្វើចំណាកស្រុក ជាញឹកញាប់ ស្ត្រីត្រូវរង់ចាំការយល់ព្រមពីបុរស(នៅពេលត្រឡប់មកវិញ ឬតាមទូរស័ព្ទ) មុននឹងសម្រេចសង់បង្គន់ក្នុងគ្រួសារ (Sue Cavill pers. comm. 2017, យោងតាមប្រទេសនេប៉ាល់ និងម៉ាឡាវី)។ ស្ត្រីមិនសូវទទួលបានការពិគ្រោះយោបល់ទេ៖ ក្នុងតំបន់ Odisha ប្រទេសឥណ្ឌា បុរសដែលជាមេគ្រួសារគឺជាអ្នកសម្រេចចិត្តតែម្នាក់គត់លើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធអនាម័យក្នុងគ្រួសារ ៨០%។ ក្នុងគ្រួសារ ១១% បុរសត្រូវបានពិគ្រោះយោបល់ ឬពាក់ព័ន្ធនឹងស្ត្រី។ មានគ្រួសារតែ ៩% ប៉ុណ្ណោះ ដែលមានស្ត្រីជាអ្នកសម្រេចចិត្ត (Routary et al. 2017)។ ការសិក្សាមួយក្នុងប្រទេសវៀតណាម (Leahy et al. 2017) រកឃើញថា បុរសមានឆន្ទៈចំណាយលើការសង់បន្ទប់ទឹកដែលមានបង្គន់កាច់ទឹក ជាងស្ត្រី។ មានលទ្ធផលរកឃើញស្រដៀងគ្នាក្នុងប្រទេសទីម័រខាងកើត

ដែលការសង់បង្គន់ចាក់-កាច់ទឹក ច្រើនតែជាការសម្រេចចិត្តរបស់បុរស សូម្បីតែក្នុងទីតាំងដែលខ្សត់ទឹក ព្រោះវាពាក់ព័ន្ធនឹងស្ថានភាព។ ចំណុចនេះអាចបង្កើនបន្ទុកការងាររបស់ស្ត្រី ព្រោះត្រូវដងទឹកកាន់តែច្រើន និងសម្អាតបង្គន់កាន់តែញឹកញាប់។

## ការផ្តោតលើបុរសក្នុងមុខរបរអនាម័យ

បុរសមានតួនាទីរកប្រាក់ចំណូលផ្លូវការក្នុងវិស័យអនាម័យច្រើនជាងស្ត្រី និងជាទូទៅដើរតួនាទីកាន់តែសកម្មក្នុងសហគ្រាសខ្នាតតូច។ នេះជាចំណុចល្អ និងជាតួនាទីដែលបុរសអាចធ្វើបានជាទូទៅ។ ប៉ុន្តែផ្អែកតាមទស្សនៈយេនឌ័រ ប្រការសំខាន់ត្រូវធានាថាបុរសមិន "រាំងស្ទះ" ការចូលរួមរបស់ស្ត្រី។ ការសិក្សាស្តីពីអាជីវកម្មទឹកស្អាតនិងអនាម័យក្នុងប្រទេសឥណ្ឌូនេស៊ី វៀតណាម និងទីម័រខាងកើត រកឃើញថា ក្រុមហ៊ុនទីផ្សារអនាម័យគ្រប់គ្រងភាគច្រើនដោយបុរស (Willetts et al. 2016; Leahy et al. 2017)។ ក្នុងមជ្ឈដ្ឋានជាច្រើន តួនាទីផ្លូវការក្នុងសង្វាក់ផ្គត់ផ្គង់អនាម័យឆ្លុះបញ្ចាំងពីតួនាទីប្រពៃណីសម្រាប់ស្ត្រី និងបុរស។ ជាទូទៅ បុរសត្រូវបានដាក់បញ្ចូលក្នុងតួនាទីអ្នកជំនាញបច្ចេកទេសក្នុងផ្នែករចនា ហិរញ្ញវត្ថុ សំណង់ និងការងារបូមបង្គន់។ ក្នុងប្រទេសបង់ក្លាដេស និងប្រទេសកម្ពុជា iDE រាយការណ៍ថា ជាទូទៅ ប្តីជាម្ចាស់សហគ្រាសធុនតូច និងទទួលខុសត្រូវលើការផលិត ចំណែកប្រពន្ធជាអ្នកគ្រប់គ្រងបញ្ជី ធ្វើទីផ្សារ និងសេវាអតិថិជន។ ក្នុងប្រទេសម៉ាឡាវី ជាងសំណង់ (បុរស) ត្រូវបានស្នើឱ្យបង្កើតសារឬពាក្យស្លោកដែលបង្ហាញពីលក្ខណៈសំខាន់ៗនៃបង្គន់ដែលមានតម្លៃសមរម្យ និងជាប់ធន់ក្នុងការរចនា ការធ្វើទីផ្សារ និងការបង្កើតគំរូអាជីវកម្មអនាម័យ (UNICEF 2015b)។ ការលើកឡើងរបស់ជាងសំណង់ទាំងនោះគឺ "បង្គន់អាចប្រើប្រាស់បានរាប់ឆ្នាំ សម្រាប់បុរសពិត"។ សារនេះចង់មានន័យថា បុរសកំពុងសង់បង្គន់ឡើងវិញនាពេលបច្ចុប្បន្ន។ សត្វដំរីត្រូវបានប្រើប្រាស់ជារូបសញ្ញា។

ពាក់ព័ន្ធនឹងការផ្លាស់ប្តូរទៅរកសមភាពយេនឌ័រ នេះជាផ្នែកមួយទៀតដែលគេអាចសម្រេចបានសមភាពយេនឌ័រ តាមរយៈប្តីដែលគាំទ្រឱ្យប្រពន្ធតួនាទី ក្នុងអាជីវកម្មអនាម័យ។ ឧ. ក្នុងប្រទេសបង់ក្លាដេស អង្គការភ្លែនអន្តរជាតិបានបញ្ចុះបញ្ចូលបុរសឱ្យជំរុញប្រពន្ធរបស់ខ្លួន អភិវឌ្ឍសង្វាក់ផលិតកម្មសំឡីអនាម័យក្នុងអាជីវកម្មអនាម័យរបស់ខ្លួន។




Robust corbeled latrine, 2016. *Credit: UNICEF Malawi/PSI.*

## ២.បុរសក្នុងនាមជាភ្នាក់ងារនៃការផ្លាស់ប្តូរ

ឯកសារដែលយកមកពិនិត្យឡើងវិញ មានឧទាហរណ៍មួយចំនួនស្តីពីបុរស និងក្មេងប្រុស ដែលដើរតួនាទីជាភ្នាក់ងារនៃការផ្លាស់ប្តូរ ដើម្បីគាំទ្រឱ្យមានការលើកកម្ពស់ការអនុវត្តអនាម័យល្អប្រសើរ។

## ការផ្តោតលើបុរសក្នុងមុខរបរអនាម័យ

- បេសកកម្មឥណ្ឌាស្អាតរបស់ Narendra Modi ឬយុទ្ធនាការសង់បង្គន់ទូទាំងប្រទេស Mtu ni Afya របស់ Mwalimu Julius Nyerere ក្នុងប្រទេសតង់ហ្សានី នៅអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០។ ក្នុងប្រទេសកេនយ៉ា លោកបណ្ឌិត Kepha Ombacho ប្រធាននាយកដ្ឋានសុខភាពសាធារណៈនៃក្រសួងសុខាភិបាលកេនយ៉ា បានដឹកនាំការពិនិត្យឡើងវិញលើគោលនយោបាយ និងការរៀបចំគោលការណ៍ណែនាំដើម្បីធានាថាប្រទេស និងអ្នកពាក់ព័ន្ធទាំងអស់ចូលរួមក្នុងយុទ្ធនាការអនាម័យ (Wamera, pers.comm.2018)។

## បុរសនៅកម្រិតសហគមន៍

- អ្នកដឹកនាំសហគមន៍អាចឥទ្ធិពលលើទស្សនៈសាធារណៈ តាមបែបស៊ីជម្រៅ និងបង្គាប់បញ្ជា និងអាចជាភ្នាក់ងារផ្លាស់ប្តូរដ៏មានអនុភាព។ ប្រធាន Macha បានដឹកនាំយុទ្ធនាការសហគមន៍ដឹកនាំអនាម័យទាំងស្រុង "គ្មានលាមក! គ្រួសារមួយ បង្គន់មួយ! ក្នុងតំបន់ Choma នៃប្រទេសហ្សាំប៊ី ជាយុទ្ធនាការដែលអ្នកដឹកនាំបែបប្រពៃណីគាំទ្រកិច្ចខិតខំប្រឹងប្រែងផ្លាស់ប្តូរអនាម័យជនបទ។

- ក្នុងប្រទេសទីម័រខាងកើត ទិន្នន័យពីកម្មវិធី BESIK (Bee no Sanimentu iha Komunidade៖ កម្មវិធីផ្គត់ផ្គង់ទឹក និងអនាម័យជនបទ) បានបង្ហាញពីអត្រាខ្ពស់ជាបន្តបន្ទាប់នៃការចូលរួមរបស់បុរសក្នុងព្រឹត្តិការណ៍ និងកិច្ចប្រជុំសហគមន៍ (ស្ត្រីមិនអាចចូលរួមបានដោយសារបន្ទុកកិច្ចការផ្ទះ)។

- ក្នុងស្រុក Bombali ប្រទេសសេរ៉ាឡេអូន សហគមន៍ត្រូវបានបែងចែកជាក្រុមដើម្បីរៀបចំការសង់បង្គន់ក្នុងផ្នែកផ្សេងៗរបស់សហគមន៍ (កម្រងគ្រួសារ)។ ក្នុងកម្រងនីមួយៗ ពួកគេបង្កើតជា ៣ ក្រុម (ក្រុមបុរស ក្រុមស្ត្រី និងក្រុមយុវជន) ហើយក្រុមនីមួយៗមានកិច្ចការរៀងខ្លួន។ បុរសកាប់ឈើ ចំណែកស្ត្រីជាអ្នករែកអុសមកភូមិ។ ស្ត្រីជញ្ជូនខ្សាច់ ទឹក អុស ផាងត្នោត និងស្បូវត្រឡប់មកភូមិ។ ក្រុមយុវជនរៀបចំការជីករណ្តៅបង្គន់។ ស្ត្រីចាក់ពុម្ពឥដ្ឋ ចំណែកបុរស និងយុវជនជាអ្នកសង់ចានបង្គន់ ជញ្ជាំង និងដំបូលបង្គន់ ហើយស្ត្រីជាអ្នកបូកផ្ទៃជញ្ជាំងបង្គន់ (UNICEF CLTS Evaluation 2011)។

- ក្នុងក្រុមគោលដៅមួយនៅតំបន់ Tororo ប្រទេសអ៊ុយហ្គង់ដា (ខែ កក្កដា ឆ្នាំ ២០១២) ក្មេងប្រុសមួយក្រុមនិយាយថា ពួកគេយល់ថារងការមាក់ងាយពីមិត្តភក្តិ ប្រសិនបើពួកគេមិនប្រើបង្គន់៖ ប្រសិនបើអ្នកមិនប្រើបង្គន់ ក្មេងផ្សេងទៀតអាចចំអកឱ្យអ្នក។ អ្នកត្រូវបានចាត់ទុកជាមនុស្សទាបថោក" (Kidd, pers. comm.)។

### បុគ្គលល្បីឈ្មោះដែលជំរុញទឹកចិត្ត/មានប្រជាប្រិយភាព

- ការប្រើប្រាស់បុគ្គលគំរូពាក់ព័ន្ធនឹង "បុរសដែលអ្នកចង់យកគំរូតាម"។ បុរសល្បីឈ្មោះដើរតួនាទីជាភ្នាក់ងារផ្លាស់ប្តូរក្នុងបេសកកម្ម Swachh Bharat។ អ្នកសម្តែង ផលិតករ អ្នករៀបចំកម្មវិធីទូរទស្សន៍ និងអតីតអ្នកនយោបាយលោក Amitabh Bachchan បានលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរឥរិយាបថក្នុងចំណោមបុរសដែលមានបង្គន់ តែមិនប្រើ ហើយអតីតប្រធានក្រុមជម្រើសជាតិក្រិកកែត Sachin Tendulkar បានធ្វើជាប្រធានក្រុមល្បែង WASH United និងក្រុម Swachh Bharat របស់ UNICEF។

### បុរសដែលប្រើប្រាស់តួនាទីក្នុងការងាររបស់ខ្លួនដើម្បីធ្វើជាភ្នាក់ងារផ្លាស់ប្តូរ

- បុរសមួយចំនួន មានអំណាចក្នុងការលើកកម្ពស់ការផ្លាស់ប្តូរ ដោយសារតែតួនាទីក្នុងស្ថាប័ន ឬការងាររបស់ខ្លួន។ នៅប្រទេសនីហ្សេរីយ៉ា អ្នកបើក okada (អ្នករត់ម៉ូតូឌុប ដែលភាគច្រើនលើសលប់ជាបុរស) គឺជាក្រុមអ្នកពាក់ព័ន្ធដ៏សំខាន់ នៅទីប្រជុំជនក្នុងសកម្មភាពសហគមន៍ដឹកនាំអនាម័យទាំងស្រុង ព្រោះជាញឹកញាប់ពួកគេដឹកមនុស្សទៅមកសហគមន៍ជនបទ។ ប្រសិនបើអ្នកបើក okada មិនយល់ដឹង ឬមិនត្រូវបានបំផុសទេ ពួកគេអាចរាំងស្ទះសហគមន៍ដែលគ្មានការបន្ទោរបង់ពាសវាលពាសកាល ដោយមិនដឹងខ្លួន តាមរយៈការបន្ទោរបង់ក្នុងគុម្ពោតព្រៃ (UNICEF 2010)។

### អ្នកដឹកនាំសាសនា/ជំនឿ ចាស់ព្រឹទ្ធាចារ្យក្នុងសហគមន៍ ឬព្រះសង្ឃ

- ក្នុងស្រុក Nuh ប្រទេសឥណ្ឌា Imams បានប្រកាសក្នុងព្រះវិហារថា ពួកគាត់នឹងមិនធ្វើពិធី nikah (ពិធីរៀបការ) ក្នុងគ្រួសារណាដែលគ្មានបង្គន់ ឬបន្ទោរបង់ពាសវាលពាសកាលនោះទេ (Satyavada នឹងបោះពុម្ពផ្សាយឆាប់ៗនេះ 2018)។ Fatwa ឬក្រឹត្យឥស្លាម ដែលកំណត់ដោយក្រុមប្រឹក្សាបញ្ញវន្តឥស្លាមឥណ្ឌូនេស៊ី បានរៀបរៀងសៀវភៅធម្មទេសនាមួយក្បាល សម្រាប់អ្នកដឹកនាំសាសនា ក្នុងមូលដ្ឋានដើម្បីផ្តល់ការណែនាំផ្នែកជំនឿស្តីពីទឹកស្អាត និងអនាម័យក្នុងពិធីសូត្រធម៌ថ្ងៃសុក្រ និងជំរុញឱ្យមនុស្សផ្លាស់ប្តូរទម្លាប់អនាម័យដែលគ្មានសុវត្ថិភាព (Cronin 2016)។ ស្រុកមួយក្នុងប្រទេសកម្ពុជាបានក្លាយជាស្រុកគ្មានការបន្ទោរបង់ពាសវាលពាសកាល មួយផ្នែកដោយសារតែព្រះសង្ឃដាក់សម្ពាធលើគ្រួសារដែលគ្មានបង្គន់។ ព្រះសង្ឃមានសង្ឃដីកាថានឹងមិនសូត្រធម៌នៅផ្ទះដែលគ្មានបង្គន់នោះទេ (Tyndale-Biscoe, pers. comm.)។ អ្នករៀបចំកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុងក្នុងប្រជុំកោះសូឡូម៉ូន បានចងសម្ព័ន្ធជាមួយប្រធានព្រះវិហារ និងប្រើប្រាស់អត្ថបទសាសនា។ ឧ. អត្ថបទទូទៅបំផុត ដែលត្រូវបានដកស្រង់ពី Deuternomy 23:13 គឺ "កាន់ដំបងមួយតាមខ្លួន។ ដូច្នេះនៅពេលអ្នកចង់បន្ទោរបង់ អ្នកអាចជីករណ្តៅសម្រាប់បន្ទោរបង់ រួចកាយកប់"។

- បណ្ដាញក្ដីសង្ឃឹម សម្រាប់យេនឌ័រ របស់អង្គការទស្សនៈពិភពលោក គឺជាឧទាហរណ៍មួយនៃរបៀបជំរុញការចូលរួមរបស់អ្នកដឹកនាំ សាសនា/ជំនឿ ក្នុងដំណើរការផ្លាស់ប្ដូរទំនាក់ទំនង និងបទដ្ឋានយេនឌ័រ។ ជំហានដំបូង គឺត្រូវជះឥទ្ធិពលលើផ្នត់គំនិតរបស់ពួកគេ។

### ការគ្រប់គ្រងអនាម័យក្នុងពេលមករដូវ

មានការយល់ដឹងកាន់តែច្រើនក្នុងវិស័យទឹកស្អាត និងអនាម័យស្ដីពីភាពចាំបាច់នៃការផ្ដោតលើការគ្រប់គ្រងអនាម័យ ក្នុងពេលមករដូវ ក្នុងអន្តរាគមន៍អនាម័យ។ បុរសឆ្នើមនៅជុំវិញពិភពលោកបាន និងកំពុងជួយលុបបំបាត់របាំង និងតំណមនានាដោយសហការជាមួយស្ត្រី និងក្រុមស្ត្រី។

- ក្រុមប្រឹក្សាកិច្ចសហការផ្គត់ផ្គង់ទឹក និងអនាម័យ (WSSCC) បានផ្ដល់ជំនួយមូលនិធិដល់ការបណ្ដុះបណ្ដាលគ្រូបង្គោល ស្ដីពីការគ្រប់គ្រងអនាម័យក្នុងពេលមករដូវនៅប្រទេសកេនយ៉ា ដែលរួមបញ្ចូលបុរសផងដែរ។ អភិបាលតំបន់ជនជាតិកេនយ៉ាម្នាក់ បានគាំទ្រការងាររបស់ប្រពន្ធគាត់ក្នុងការលើកកម្ពស់ការគ្រប់គ្រងអនាម័យក្នុងពេលមករដូវ ព្រមទាំងបានផ្ដល់ហិរញ្ញវត្ថុផ្ទាល់ខ្លួនដល់គំនិតផ្ដួចផ្ដើមបង្កើតផលិតផលអនាម័យ ក្នុងប្រទេសរបស់គាត់ទៀតផង។ ជំនួយការស្នងការស្រុកម្នាក់ ដែលរាយការណ៍ផ្ទាល់ទៅខុទ្ទកាល័យប្រធានាធិបតីកេនយ៉ា បានឡើងថ្លែងពីការគ្រប់គ្រងអនាម័យក្នុងពេលមករដូវនៅនៅសាលារៀន និងកិច្ចប្រជុំសហគមន៍ក្នុងអាណត្តិ និងសំលៀកបំពាក់ផ្លូវការរបស់ខ្លួន (Wamera, pers. comm. 2018)។

- ផ្នែកមួយ នៃភាពជាដៃគូរបស់អង្គការទស្សនៈពិភពលោក ជាមួយ Sesame Workshop គឺកម្មវិធី "ការជជែករបស់ក្មេងស្រី" ដែលជាកម្មវិធីសិក្សាដែលផ្ដោតលើភាពពេញវ័យ និងការអប់រំពីការមករដូវ ដែលបង្កឲ្យមានការចូលរួមទាំងសិស្សប្រុស និងសិស្សស្រី ក្នុងការស្វែងយល់ និងការលើកកំពស់ការគ្រប់គ្រងអនាម័យក្នុងពេលមករដូវ។ គម្រោងនេះកំពុងត្រូវបានអនុវត្តសាកល្បងក្នុងសាលារៀន ២០០ ទូទាំងប្រទេសហ្ស៊ីមបាវ៉េ។

## ៣.បុរសក្នុងនាមជាដៃគូនៃការផ្លាស់ប្ដូរ

បុរសក៏ដើរតួនាទីជាដៃគូដែលសហការជាមួយស្ត្រី ដើម្បីធ្វើឱ្យមានការផ្លាស់ប្ដូរក្នុងកម្មវិធីអនាម័យផងដែរ។ មានឧទាហរណ៍ដែលបុរសបានជួយរក្សាតុល្យភាពយេនឌ័រ តាមរយៈការទទួលខុសត្រូវលើអនាម័យ (ក្នុងកន្លែងធ្វើការ គ្រួសារ ឬសហគមន៍) គាំទ្រស្ត្រីឱ្យធ្វើជាអ្នកដឹកនាំក្នុងវិស័យអនាម័យ ឬជំរុញការពិចារណាស្ដីពីយេនឌ័រក្នុងចលនាអនាម័យ។

## បុរសគាំទ្រឱ្យស្ត្រីដឹកនាំសកម្មភាពអនាម័យ

មានឯកសារយ៉ាងច្រើនស្តីពការចូលរួម និងការដឹកនាំរបស់បុរសក្នុងដំណើរការទឹកស្អាត និងអនាម័យ ប៉ុន្តែមិនសូវមានឯកសារស្តីពីការគាំទ្ររបស់បុរសចំពោះការចូលរួមរបស់ស្ត្រីក្នុងការដឹកនាំអនាម័យ ឬដំណើរការធ្វើសេចក្តសម្រេចចិត្តឡើយ។ បទពិសោធន៍ក្នុងប្រទេសទីម័រខាងកើតបង្ហាញពី ភាពចាំបាច់នៃការផ្តោតលើការកសាងទំនុកចិត្តរបស់ស្ត្រី និងការលើកទឹកចិត្ត (ដោយបុរស) ឱ្យស្ត្រីឡើងនិយាយក្នុងកិច្ចប្រជុំដើម្បីធ្វើយ៉ាងណាកុំឱ្យបុរសធ្វើជាអ្នកសម្រេចចិត្តតែឯង។ ស្វ័យទំនុកចិត្តត្រូវបានលើកឡើងជាបញ្ហាដ៏សំខាន់មួយក្នុងការលើកកម្ពស់ភាពជាអ្នកដឹកនាំរបស់ស្ត្រី ទោះបីជាបុរសផ្តល់ឱកាសឱ្យស្ត្រីក៏ដោយ។ អង្គការទស្សនៈពិភពលោកកត់សម្គាល់ថា ខណៈដែលគណៈកម្មាធិការទឹកស្អាត និងអនាម័យអាចមានសមាសភាគយេនឌ័រស្មើភាពសម្រាប់មុខតំណែងក្នុងគណៈកម្មាធិការនេះ សមាជិកជាស្ត្រីប្រហែលជាគ្មានសំឡេងស្មើភាពនឹងបុរសឡើយ។ ការអនុវត្ត ឬ "ការអនុញ្ញាត" ពីប្តី និងតួនាទីយេនឌ័របែបប្រពៃណីក្នុងផ្ទះ អាចជាឧបសគ្គរាំងការចូលរួមយ៉ាងសកម្មរបស់ស្ត្រី។ បុគ្គលិកម្នាក់របស់អង្គការទស្សនៈពិភពលោកក្នុងប្រទេសហ្កាណាកត់សម្គាល់ថា *"ស្ត្រីមិនគួរនិយាយនៅចំពោះមុខជនប្លែកមុខទេ ប្រសិនបើប្តីមិនអនុញ្ញាតឱ្យធ្វើដូច្នេះ"* (UNC and World Vision n.d.: p.2)។ បុរសមានតួនាទីសម្របសម្រួលឱកាសសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តរបស់ស្ត្រីក្នុងដំណើរការអនាម័យ។

នៅឆ្នាំ ២០១២ អង្គការភ្លែនសេរ៉ាឡេអូន បានធ្វើការស្រាវជ្រាវពីតួនាទីរបស់ស្ត្រីក្នុងកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង និងរកឃើញថា ស្ត្រីមិនបានចូលរួមច្រើនដូចបុរសក្នុងកិច្ចប្រជុំបំផុសទេ។ ស្ត្រីពន្យល់ថា "ពួកគេចង់ឱ្យប្តី ឬបុរសផ្សេងទៀតចូលរួមពិភាក្សាល្អជាង"។ ផ្អែកតាមលទ្ធផលនៃការសិក្សានេះ អង្គការភ្លែនបានផ្តោតជាសំខាន់ និងផ្តល់ជំនាញសម្រាប់ការជំរុញឱ្យស្ត្រីចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំបំផុស ដើម្បីឱ្យស្ត្រីមានសំឡេង និងចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តស្តីពីដំណើរការគ្មានការបន្ទោរបង់ពាសវាលពាសកាល និងរក្សាស្ថានភាពនេះ។ អង្គការភ្លែនបានបង្កើតបទដ្ឋានថ្មីៗសម្រាប់ការចូលរួមរបស់ស្ត្រី ដោយធ្វើយ៉ាងណាឱ្យគ្រប់គ្នាទទួលស្គាល់ថា ទស្សនៈរបស់ស្ត្រីត្រូវបានគេគោរព និងឱ្យតម្លៃ។ អង្គការភ្លែនបានរៀបចំឡើងវិញនូវគោលការណ៍ណែនាំសម្រាប់ការជ្រើសរើសអ្នកដែលមានទេពកោសល្យជាអ្នកដឹកនាំពីកំណើត ក្នុងសហគមន៍ ដើម្បីឱ្យមានការជ្រើសរើសស្ត្រីឱ្យបានច្រើន (ផលធៀប ២:៣) (Kidd, pers.comm.)។

## ការថែទាំដែលពាក់ព័ន្ធនឹងអនាម័យ

មានការការផ្តោតយ៉ាងច្រើនលើតួនាទីថែទាំក្នុងកិច្ចពិភាក្សាអភិវឌ្ឍន៍យ៉ាងទូលំទូលាយ ប៉ុន្តែមិនសូវមានការផ្តោតលើអនាម័យទេ។ យុទ្ធនាការអន្តរជាតិ ដូចជា MenCare, He for She, Promundo និង We Can បានសហការជាមួយបុរស និងក្រុមអ្នកដែលមានវ័យ និងបទពិសោធន៍ស្របាលគ្នា ដើម្បីផ្លាស់ប្តូរបទដ្ឋានយេនឌ័រ ដូចជា ការតស៊ូមតិឱ្យបុរសធ្វើកិច្ចការថែទាំក្នុងគ្រួសារឱ្យបាន ៥០%។ ទីភ្នាក់ងារទឹកស្អាត និងអនាម័យត្រូវដាក់

បញ្ចូលរបៀបវារៈនេះ។

ទីភ្នាក់ងារទឹកស្អាត និងអនាម័យ បានទទួលស្គាល់ និងរក្សាតុល្យភាពរវាងការប្រើប្រាស់យុទ្ធនាការដែលមានប្រសិទ្ធភាព ដោយសារតែទីភ្នាក់ងារទាំងនោះទាញប្រយោជន៍ពីបទដ្ឋានយេនឌ័រ (និងពង្រឹងបទដ្ឋានទាំងនោះដោយប្រយោល) និងការអនុវត្តវិធីសាស្ត្រផ្សេងៗដែលដេញដោលបទដ្ឋាននានា។ យុទ្ធនាការគួរមានសមាសភាគរំខានក្នុងការដេញដោលបទដ្ឋានយេនឌ័រដែលលើកកម្ពស់ការអនុវត្តអវិជ្ជមាន។ មានការចងក្រងតិចតួចពីឧទាហរណ៍ទាំងនេះក្នុងវិស័យទឹកស្អាត និងអនាម័យ។

**ការដេញដោលបទដ្ឋានយេនឌ័រតាមរយៈកម្មវិធីទឹកស្អាត និងអនាម័យក្នុងប្រទេសទីម័រខាងកើត**

WaterAid បានប្រើប្រាស់កម្មវិធីទឹកស្អាត និងអនាម័យជាចំណុចចាប់ផ្តើមនៃការដេញដោលបទដ្ឋានយេនឌ័រក្នុងប្រទេសទីម័រខាងកើត។ សៀវភៅណែនាំស្តីពីកិច្ចសន្ទនា ក្នុងសហគមន៍ត្រូវបានផលិតឡើងជាមគ្គុទេសក៍សម្រាប់ការដាក់បញ្ចូលវគ្គស្វែងយល់ពីយេនឌ័រ និងកិច្ចសន្ទនារវាងស្ត្រី និងបុរសក្នុងដំណើរការរៀបចំផែនការកម្មវិធីទឹកស្អាត និងអនាម័យ។ សៀវភៅណែនាំនេះមានគោលបំណងបង្កើតចំណេះដឹងរួមស្តីពីតួនាទី និងទំនាក់ទំនងយេនឌ័រ និងរបៀបផ្លាស់ប្តូរបន្ទុកការងារឱ្យកាន់តែមានយុត្តិធម៌។ លទ្ធផលមួយចំនួនដែលបានលើកឡើងគឺ បុរសកំពុងផ្តល់ឱកាសឱ្យស្ត្រីឡើងនិយាយក្នុងកិច្ចប្រជុំសហគមន៍ និងក្រុមគ្រប់គ្រង។ ស្ត្រីម្នាក់និយាយថា៖ ខ្ញុំភ្ញាក់ផ្អើលចំពោះប្តីរបស់ខ្ញុំដែលបានចូលរួមវគ្គយេនឌ័រ ដែលនិយាយពីការងារស្មើភាពរវាងបុរស និងស្ត្រី។ វាមិនទាន់ជាការផ្លាស់ប្តូរច្រើននោះទេ ប៉ុន្តែជាញឹកញាប់គាត់ចេះសួរខ្ញុំពីកិច្ចការផ្ទះដែលខ្ញុំកំពុងធ្វើ ហើយគាត់ចាប់ផ្តើមជួយធ្វើកិច្ចការមួយចំនួនតែម្តង។ គាត់ក៏ជួយមើលកូនញឹកញាប់ដែរ ដូចជា ងូតទឹកឱ្យកូនឬលាងគូថកូន។

ប្រភព ៖ WaterAid 2016

## របៀបពង្រឹងកម្មវិធី និងដំណើរការអនាម័យ

គោលការណ៍ខាងក្រោមជាមូលដ្ឋានសម្រាប់ការពង្រឹងកម្មវិធី និងដំណើរការអនាម័យ៖

**គោលការណ៍សម្រាប់ការធ្វើការជាមួយស្ត្រី និងបុរសក្នុងកម្មវិធីទឹកស្អាត និងអនាម័យ**

**គោលការណ៍ទី ១៖** សម្របសម្រួលការចូលរួម និងការរួមបញ្ចូល ដើម្បីឱ្យគ្រប់គ្នាអាចចូលរួមក្នុងការកែលម្អកម្មវិធីទឹកស្អាត និងអនាម័យ។

**គោលការណ៍ទី ២៖** អនុវត្តដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលបំផុសការចូលរួមយ៉ាងសកម្មរបស់បុរស និងស្ត្រីក្នុងគម្រោង និងសកម្មភាពនានា។

**គោលការណ៍ទី ៣៖** យល់និងឱ្យតម្លៃភាពខុសគ្នានៃការងារជំនាញនិងការព្រួយបារម្ភរបស់ស្ត្រី និងបុរស។

**គោលការណ៍ទី ៤៖** បង្កើតឱកាសសម្រាប់ឱ្យបុរស និងស្ត្រីដកពិសោធន៍និងចែករំលែកតួនាទី និងការទទួលខុសត្រូវថ្មីៗ។

ប្រភព ៖ Halcrow et al.2010

ទោះបីជាគោលការណ៍ទាំងនេះផ្តោតលើតួនាទីក្នុងសហាគមន៍សម្រាប់បុរស និងស្ត្រីក្តី ប៉ុន្តែចាំបាច់ត្រូវមានការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើតួនាទីរបស់ស្ត្រីក្នុងនាមជាអ្នកជំនាញទឹកស្អាត និងអនាម័យផងដែរ។ ប្រសិនបើមានការផ្លាស់ប្តូរពីខាងក្នុងតួអង្គក្នុងកម្មវិធីទឹកស្អាត និងអនាម័យ នឹងអាចដឹកនាំដោយផ្អែកតាមគំរូនៃរបៀបដែលពួកគេគាំទ្រដល់សហាគមន៍ដែលពួកគេធ្វើការ។ ខាងក្រោមនេះជាវិធីជាក់ស្តែងមួយចំនួនក្នុងការពង្រឹងការផ្តោតលើបុរស និងក្មេងប្រុសក្នុងដំណើរការអនាម័យ៖

## ក.បរិយាកាសអំណោយផល

ធានាការអនុវត្តគោលការណ៍ណែនាំ ហើយឯកសារបណ្តុះបណ្តាលត្រូវរួមបញ្ចូលការផ្តោតលើបុរស និងក្មេងប្រុស ព្រមទាំងរៀបចំវគ្គបណ្តុះបណ្តាលអនុវត្តន៍សមស្របស្តីពីចំណុចនេះ ដោយអ្នកឯកទេសក្នុងវិស័យទឹកស្អាត និងអនាម័យ និងអ្នកឯកទេសយេនឌ័រ។

## ខ.កម្រិតកម្មវិធី និងកម្រិតសហាគមន៍ មុនពេលអនុវត្តន៍

ដំណាក់កាលមុនពេលអនុវត្តន៍ មានសារៈសំខាន់ណាស់សម្រាប់ការចាប់ផ្តើមស្វែងយល់ពីបញ្ហាយេនឌ័រក្នុងសហាគមន៍។ មានឧបករណ៍ជំរុញការចូលរួមមួយចំនួនដែលត្រូវបានសាកល្បង និងធ្វើតេស្ត ដើម្បីជួយឱ្យក្រុមកម្មវិធីស្វែងយល់ពីតួនាទី និងការទទួលខុសត្រូវយេនឌ័រក្នុងសហាគមន៍គោលដៅ មុននឹងចាប់ផ្តើមអនុវត្តន៍ (ឧ.អ្នកសម្អាតបង្គន់ អ្នកជួយដល់កុមារ និងអ្នកផ្សេងទៀតក្នុងការប្រើប្រាស់បង្គន់។ល។)។

- ឧបករណ៍ ដូចជា ការចូលរួមសកម្មភាពអនាម័យ ដែលជំរុញឱ្យមានការផ្លាស់ប្តូរ (PHAST) និងវដ្តនៃការរៀនសូត្រ នាឡិកា ២៤ ម៉ោង និងដូងអណ្តែត (floating coconut) សុទ្ធតែអាចបង្ហាញពីបន្ទុកការងារពាក់ព័ន្ធនឹងទឹកស្អាត និងអនាម័យរបស់បុរស និងស្ត្រីក្នុងគ្រួសារ និងសហាគមន៍ និងធ្វើឱ្យមានការពិភាក្សាពីរបៀបចែករំលែកបន្ទុកការងារអនាម័យ។
- ធ្វើការជាមួយសហាគមន៍ និងអ្នកដឹកនាំសាសនា/ជំនឿ ដើម្បីជះឥទ្ធិពលលើឥរិយាបថរបស់ក្មេងប្រុស និងបុរស និងផ្តល់ឱកាសឱ្យស្ត្រីឡើងនិយាយ (ជាជាងឱ្យបុរសឡើងនិយាយជំនួស)។

- ប្រើកិច្ចប្រជុំ មុនពេលបំផុស ដើម្បីតស៊ូមតិឱ្យបុរសចូលរួមក្នុងកិច្ចប្រជុំបំផុស និងបញ្ចុះបញ្ចូលឱ្យមេភូមិប្តេជ្ញាសម្រេចគោលបំណងនេះ។
- ធានាថា យុទ្ធនាការអនាម័យមិនពង្រឹងភាពលម្អៀងយេនឌ័រ។

## ក្នុងពេលអនុវត្តកម្មវិធី

ការជំរុញការចូលរួមរបស់បុរស និងក្មេងប្រុសក្នុងក្នុងការអនុវត្តកម្មវិធី អាចធ្វើឡើងតាមរបៀបដែលដេញដោលបទដ្ឋាន តួនាទី នឹងភាពលម្អៀងយេនឌ័រ។

- ធ្វើការបំផុស និងរៀបចំព្រឹត្តិការណ៍ពាក់ព័ន្ធនឹងយុទ្ធនាការផ្សេងទៀត នៅពេលវេលា និងទីតាំងដែលផ្តល់ភាពងាយស្រួលដល់បុរស និងស្ត្រី។ កុំសន្មតថាបុរសនឹងបានដឹងពីការបំផុស។ ត្រូវចុះជួបពួកគាត់តាមផ្ទះ ឬកន្លែងធ្វើការដើម្បីលើកទឹកចិត្តឱ្យពួកគាត់ចូលរួមក្នុងវគ្គបំផុសទូទាំងសហគមន៍។
- អញ្ជើញឱ្យបុរសចូលរួមក្នុងកិច្ចប្រជុំបំផុស ហើយនៅពេលមានវត្តមានតិច សូមកុំចាប់ផ្តើមកិច្ចប្រជុំ។ សូមកៀរគរបុរសឱ្យចូលរួមមុននឹងចាប់ផ្តើម (នេះជាអ្វីដែលបានធ្វើឡើងនៅប្រទេសទីម័រខាងកើត)។
- ប្រើប្រាស់ជំនាញរបស់អ្នកសម្របសម្រួល ដើម្បីជំរុញបុរសឱ្យគាំទ្រស្ត្រីឡើងនិយាយ និងរួមចំណែកដល់ការធ្វើសេចក្តីសម្រេចចិត្តក្នុងសហគមន៍។
- ប្រើប្រាស់អនុភាពកីឡា (សិទ្ធិលេងបាល់ទាត់ និងកីឡាផ្សេងទៀតសម្រាប់កម្មវិធីអភិវឌ្ឍន៍) ដើម្បីបង្កើនការចូលរួមយ៉ាងសកម្មរបស់យុវជន និងយុវតីក្នុងយុទ្ធនាការអនាម័យ។
- ទាក់ទាញចំណាប់អារម្មណ៍ពិសេសរបស់ "អ្នកកំណត់បរិយាកាស" ក្នុងក្រុមសហគមន៍ដឹកនាំអនាម័យទាំងស្រុង ដើម្បីឱ្យពួកគេក្លាយជា "ជើងឯកយេនឌ័រ" សម្រាប់ក្រុម។ អ្នកកំណត់បរិយាកាសគួរតាមដានដំណើរការកិច្ចប្រជុំ និងធ្វើអន្តរាគមន៍ដើម្បីធ្វើយ៉ាងណាឱ្យមានការផ្តោតការយកចិត្តទុកដាក់លើស្ត្រី ដូចជា ការបញ្ឈប់កិច្ចប្រជុំប្រសិនបើមិនសូវមានស្ត្រីចូលរួម និងធ្វើអន្តរាគមន៍ក្នុងកិច្ចប្រជុំ ដើម្បីឱ្យស្ត្រីមានឱកាសស្មើភាពក្នុងការនិយាយ និងមានអ្នកស្តាប់គំនិតរបស់ស្ត្រី បញ្ឈប់ការស្តីបន្ទោសស្ត្រីលើបញ្ហាកង្វះអនាម័យក្នុងគ្រួសារ និងសហគមន៍ និងការជួយឱ្យបុរសយល់ពីសារៈសំខាន់នៃការចូលរួមរបស់ស្ត្រី។
- លើកទឹកចិត្តឱ្យសហគមន៍ដាក់បញ្ចូលតួនាទីមួយ សម្រាប់ឱ្យបុរសរួមចំណែកក្នុងតួនាទីអនាម័យគ្រួសារក្នុងផែនការសកម្មភាពសហគមន៍។

## ការតាមដានបន្ត

មានឱកាសជាច្រើនដើម្បីជំរុញការចូលរួមរបស់បុរស និងក្មេងប្រុសនៅដំណាក់កាលតាមដានបន្តដើម្បីពង្រឹងលទ្ធផលដែលចង់បាន។

- លើកទឹកចិត្តឱ្យបុរស និងក្មេងប្រុសកំណត់រក "សកម្មភាពតូចៗដែលអាចធ្វើបានភ្លាមៗ"។
- ជំរុញឱ្យបុរស និងក្មេងប្រុសចែករំលែកការទទួលខុសត្រូវក្នុងគ្រួសារ និងដើរតួនាទីជាបុគ្គលគំរូក្នុងសហគមន៍។
- បង្កើតកិច្ចសន្ទនាស្ដីពីតួនាទីយេនឌ័រប្រពៃណី និងដេញដោលភាពលម្អៀងបទដ្ឋាន និងទំនាក់ទំនងយេនឌ័រអវិជ្ជមាន ដោយបុរសដែលជាអ្នកដឹកនាំសាសនា។ល។

### គ.ការពិនិត្យតាមដាន ការវាយតម្លៃ និងការរៀនសូត្រក្នុងអង្គការ

ការពិនិត្យតាមដានលទ្ធផលផ្អែកតាមយេនឌ័រក្នុងដំណើរការអនាម័យ មិនកើតឡើងជាប្រព័ន្ធក្នុងចំណោមទីភ្នាក់ងារអនុវត្តន៍ ឬបណ្ដាប្រទេសនានា និងក្នុងទ្រង់ទ្រាយធំនោះទេ។ ការប្រើប្រាស់ទិន្នន័យពិនិត្យតាមដានក្នុងការរៀបចំកម្មវិធីជាចំណុចខ្វះខាតមួយទៀតក្នុងការអនុវត្តបច្ចុប្បន្ន។

ឧបករណ៍ដ៏ល្អមួយគឺឧបករណ៍ពិនិត្យតាមដានទឹកស្អាត និងអនាម័យ និងយេនឌ័រ (២០១៨) ដែលត្រូវបានបង្កើតឡើងដោយអង្គការភ្លែនអន្តរជាតិអូស្ត្រាលី និងអង្គការភ្លែនអន្តរជាតិវៀតណាម។ ឧបករណ៍នេះជំរុញឱ្យអ្នកប្រើប្រាស់ស្វែងយល់ពីទំនាក់ទំនងផ្អែកតាមយេនឌ័រ តាមរយៈកិច្ចសន្ទនាសហគមន៍ដោយមានការសម្របសម្រួល។

- រួមបញ្ចូលទិន្នន័យបែងចែកតាមភេទក្នុងទម្រង់ពិនិត្យតាមដាន (ដូចជា ការប្រមូលទិន្នន័យដើមគ្រា និងការអង្កេតលទ្ធផល) និងការវាយការណ៍
- រិះរកវិធីពិនិត្យតាមដានការប្រែប្រួលបទដ្ឋានយេនឌ័រស្ដីពីភាពជាបុរស
- សូមចាំថា បុគ្គលិកកម្មវិធី និងដៃគូក៏ត្រូវការឱកាស និងការកសាងសមត្ថភាពដើម្បីស្វែងយល់ពីតម្លៃ ឥរិយាបថ ជំនឿ និងបទពិសោធន៍ផ្ទាល់ខ្លួនស្ដីពីយេនឌ័រ និងផ្លូវភេទផងដែរ។

## ខ្លឹមសារសង្ខេបការរៀនសូត្រសំខាន់ៗ

ផ្អែកតាមចំណុចខ្វះខាត និងការអនុវត្តល្អបំផុតក្នុងផ្នែកមុនៗ ឧទាហរណ៍ភាគច្រើនដែលពាក់ព័ន្ធនឹងអនាម័យហាក់ពង្រឹងភាពលម្អៀងយេនឌ័រសម្រាប់បុរស និងស្ត្រី។ វិធីសាស្ត្រដែលមានលក្ខណៈផ្លាស់ប្ដូរ ផ្ដោតលើអំណាច និងបុព្វសិទ្ធិរបស់បុរស ស្ថាប័ន និងឥរិយាបថរបស់តួអង្គអភិវឌ្ឍន៍ (Edstrom et al. 2015)។ ផ្អែកលើលទ្ធផលរកឃើញពីការពិនិត្យឡើងវិញនេះ និងសេចក្ដីសន្និដ្ឋានខាងលើ យើងបានលើកអនុសាសន៍សម្រាប់ជំរុញការចូលរួមរបស់បុរស និងក្មេងប្រុសក្នុងអន្តរាគមន៍អនាម័យ ដូចខាងក្រោម។

| អនុសាសន៍ | យុទ្ធសាស្ត្រ |
|---|---|
| បង្កើនការចូលរួមរបស់បុរសក្នុងដំណើរការអនាម័យ | • ប្រើប្រាស់ដំណើរការបែបចូលរួម ដើម្បីផ្លាស់ប្តូរក្តីរំពឹងទុករបស់បុរស និងស្ត្រីចំពោះគ្នាទៅវិញទៅមកពាក់ព័ន្ធនឹងអនាម័យ (ឧ. ការរំពឹងថា បុរសធ្វើជាអ្នកជំនាញបច្ចេកទេស ហើយស្ត្រីជាអ្នកសម្អាតបង្គន់)។ ចំណុចនេះអាចបង្កើនផលប៉ះពាល់ និងនិរន្តរភាពនៃការចូលរួមរបស់បុរសក្នុងសកម្មភាពអនាម័យ។ |
| បង្កើតយុទ្ធនាការដែលផ្តោតលើបុរសដើម្បីឱ្យមានការផ្លាស់ប្តូរទៅរកសមភាពយេនឌ័រក្នុងសកម្មភាពទឹកស្អាត និងអនាម័យ | • បង្កើតបរិយាកាសអំណោយផល សម្រាប់ឱ្យបុរសដើរតួនាទីកាន់តែសកម្មជាសាធារណៈ ក្នុងសកម្មភាពអនាម័យក្នុងគ្រួសារ កន្លែងធ្វើការ និងសហគមន៍។<br>• សហការ និងរៀនសូត្រពីអ្នកឯកទេសយេនឌ័រ និងយុទ្ធនាការនានា ដូចជា Promundo, He for She និង MenCare ដែលបានលើកកម្ពស់ការផ្លាស់ប្តូរ ទៅរកសមភាពយេនឌ័រដោយជោគជ័យ តាមរយៈការដេញដោល ជំនួសឱ្យពង្រឹងបទដ្ឋាន/ភាពលម្អៀងយេនឌ័រ។ |
| បង្កើនការអនុវត្តនិងឥរិយាបថអនាម័យរបស់បុរស និងក្មេងប្រុស | • ពិនិត្យតាមដានការផ្លាស់ប្តូរបទដ្ឋានសង្គមស្តីពីយេនឌ័រដែលពាក់ព័ន្ធនឹងអនាម័យ៖<br>» អាកប្បកិរិយា៖ អ្វីដែលបុរស និងស្ត្រីធ្វើ<br>» ឥរិយាបថ៖ អ្វីដែលបុរស និងស្ត្រីជឿថាពួកគេគួរធ្វើ<br>» ការរំពឹងទុកផ្អែកតាមបទពិសោធន៍៖ អ្វីដែលស្ត្រី និងបុរសជឿថាអ្នកដទៃធ្វើ និង<br>» ការរំពឹងទុកផ្អែកតាមបទដ្ឋានសង្គម៖ អ្វីដែលស្ត្រី និងបុរសជឿថា អ្នកដទៃយល់ថា ពួកគេគួរធ្វើ។<br>• គាំទ្របុរសដែលជាភ្នាក់ងារនៃការផ្លាស់ប្តូរ ក្នុងសកម្មភាពអនាម័យដើម្បីស្វែងយល់ និងអនុវត្តវិធីសាស្ត្រផ្លាស់ប្តូរទៅរកសមភាពយេនឌ័រ ដូចជា ការគាំទ្រសំឡេងនិងការចូលរួមរបស់ស្ត្រី មិនមែននិយាយជំនួសមុខឱ្យស្ត្រីនោះទេ។ល។ |

| | |
|---|---|
| **បង្កើតយុទ្ធសាស្ត្រសម្រាប់បុរសក្នុងនាមជាដៃគូសម្រាប់ការផ្លាស់ប្តូរ** | • កំណត់អត្តសញ្ញាណ និងជំរុញការចូលរួមរបស់បុរស (ជាពិសេសឪពុក និងអ្នកដែលនឹងក្លាយជាឪពុក) និងក្មេងប្រុសដែលចង់ធ្វើជាបុគ្គលគំរូ ដើម្បីលើកកម្ពស់អនាម័យក្នុងគ្រួសារ និងសហគមន៍។<br>• ជំរុញការចូលរួមរបស់អ្នកដឹកនាំសហគមន៍ និងអ្នកមានជំនាញ និងឥទ្ធិពល ដើម្បីជះឥទ្ធិពលលើឥរិយាបថរបស់បុរស និងក្មេងប្រុស។ អ្នកដឹកនាំសាសនា/ជំនឿដើរតួនាទីយ៉ាងសំខាន់ ព្រោះបទដ្ឋានយេនឌ័រអវិជ្ជមានមួយចំនួនត្រូវបានពង្រឹងក្នុងរចនាសម្ព័ន្ធ និងការបង្រៀនសាសនា។<br>• ជំរុញការចូលរួមរបស់ក្រុមបុរស (ឧ. ក្លឹបកីឡា សមាគមអ្នកជំនាញ កងទ័ព។ល។) ដើម្បីគោលបំណងអនាម័យ។ ធ្វើដូច្នេះទើបអាចផ្សព្វផ្សាយដល់បុរសដែលពិបាកចូលដល់ ឬជួបការលំបាក។ |
| **លើកឡើងពីបញ្ហាអំណាចយេនឌ័រដែលប៉ះពាល់ដល់សកម្មភាពអនាម័យ** | • កំណត់រក និងវិភាគអំណាចរបស់បុរស និងបញ្ចៀសការត្រឡប់ទៅរកយុទ្ធសាស្ត្រ ដែលពង្រឹងគំនិតការពារនិយមរបស់បុរសឬគំនិតដែលបុរសមានប្រៀបជាងស្ត្រី។<br>• លើកទឹកចិត្តឱ្យមានការរៀនសូត្រ និងការផ្លាស់ប្តូរផ្ទាល់ខ្លួនពាក់ព័ន្ធនឹងយេនឌ័រ និងផ្លូវភេទដើម្បីបង្កើនប្រសិទ្ធភាពអង្គការ និងសក្តានុពលសម្រាប់សកម្មភាពអនាម័យដែលផ្លាស់ប្តូរទៅរកសមភាពយេនឌ័រ។<br>• វិនិយោគបន្ថែមលើការជំរុញឱ្យបុរសគាំទ្រ ការដឹកនាំការធ្វើសេចក្តីសម្រេចចិត្ត និងជំនាញបច្ចេកទេសរបស់ស្ត្រីក្នុងវិស័យទឹកស្អាត និងអនាម័យ។ |
| **បង្កើតយុទ្ធសាស្ត្រដែលផ្តោតលើតួនាទីនិងការទទួលខុសត្រូវលើទឹកស្អាតនិងអនាម័យ** | • បញ្ចៀសការពង្រឹងតួនាទីយេនឌ័រប្រពៃណី និងភាពលម្អៀងយេនឌ័រអវិជ្ជមាន ក្នុងយុទ្ធនាការផ្លាស់ប្តូរឥរិយាបថអនាម័យ<br>• ជំរុញការចូលរួមរបស់បុរស ដែលចង់សហការជាមួយក្រុមស្ត្រី។ ចំណុចដំបូង គួរទទួលបានការណែនាំពីអ្នកឯកទេសយេនឌ័រ។ |

## ផែនការសម្រាប់ការស្រាវជ្រាវបន្ថែម

- វិនិយោគលើការស្រាវជ្រាវ៖ ចងក្រងឯកសារស្តីពី "ឥរិយាបថវិជ្ជមាន[3]" និងសាកល្បងវិធីសាស្ត្រល្អៗ ដើម្បីជំរុញឱ្យបុរស បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល និងផ្លាស់ប្តូរបទដ្ឋានយេនឌ័រ ដោយផ្អែកលើកម្រងឧបករណ៍ និងភស្តុតាងមានស្រាប់ក្នុងវិស័យផ្សេងៗ។ក្រៅពីនេះយើងត្រូវដឹងពីរបៀបលើកឡើងពី"ការជំរុញការចូលរួមអន្តរវិស័យ"ទន្ទឹមគ្នានឹងការព្រួយបារម្ភយេនឌ័រក្នុងកម្មវិធីអនាម័យ។

- ចាំបាច់ត្រូវមានកម្រងវិធីសាស្ត្រដែលគាំទ្រ "សកម្មភាពទឹកស្អាត និងអនាម័យដែលផ្លាស់ប្តូរទៅរកសមភាពយេនឌ័រ" ដែលអាចយកមកសាកល្បង និងកែសម្រួលតាមរយៈការអនុវត្ត និងការស្រាវជ្រាវ។ ចំណុចនេះរួមមានវិធីសាស្ត្រ និងឧបករណ៍ដែលសម្របសម្រួលឱ្យបុរសគាំទ្រការដឹកនាំ សំឡេង និងការចូលរួមរបស់ស្ត្រី ក្នុងបញ្ហាអនាម័យ។ វិធីសាស្ត្រទាំងនេះនឹងគាំទ្រដល់បទដ្ឋាននៃភាពជាបុរសវិជ្ជមាន និងទំនាក់ទំនងរវាងបុរស និងការបែងចែកការទទួលខុសត្រូវរវាងបុរស និងស្ត្រី ក្មេងប្រុស និងក្មេងស្រី។

- គំរូនៃភាពជាដៃគូ សម្រាប់ជំរុញការចូលរួមជាយុទ្ធសាស្ត្ររបស់អង្គការ ដែលធ្វើការក្នុងវិស័យទឹកស្អាត និងអនាម័យ ជាមួយអង្គការ បណ្តាញ និងចលនាស្ត្រីរួមជាមួយនឹងក្រុមបុរស លើបញ្ហាអនាម័យ (ដែលកំពុងលេចឡើងក្នុងតំបន់អាស៊ីខាងត្បូង និងខាងកើត និងប៉ាស៊ីហ្វិក)។

- ចាំបាច់ត្រូវមានការចងក្រងឯកសារឱ្យបានល្អស្តីពីរបៀបដែលជំនឿ និងឥរិយាបថរបស់អ្នកជំនាញទឹកស្អាត និងអនាម័យ និងរចនាសម្ព័ន្ធអង្គការ រួមចំណែកដល់ការមិនគិតគូរពីបទដ្ឋានយេនឌ័រអវិជ្ជមាន ឬគាំទ្រ និងជំរុញបទដ្ឋានទាំងនោះ។

[3]ឧទាហរណ៍នៃបុគ្គលលេចធ្លោរក្នុងចំណោមប្រជាជន ឬក្រុមដែលអនុវត្តតាមទិសដៅដែលចង់បាន។

# ឯកសារយោង

Ashebir, Y., Sharma, H.R., Alemu, A. and Kebede, G. (2013) 'Latrine use among rural households in Northern Ethiopia: A case study in Hawzien District, Tigray', *International Journal of Environmental Studies* 70.4: 629–636

Birchall, J., Edström, J. and Shahrokh, T. (2016) 'Reframing men and boys in policy for gender equality', *EMERGE Policy Brief*, BRIDGE, Promundo-US, Sonke Gender Justice and the Institute of Development Studies, Brighton: IDS

Chambers, R. and Myers, J. (2016) 'Norms, knowledge and usage', *Frontiers of CLTS: Innovations and Insights* 7, http://www.communityledtotalsanitation.org/sites/communityledtotalsanitation.org/files/Frontiers_7_Norms_Knowledge_Usage.pdf, Brighton: IDS (accessed 22 May 2018)

Charuka, M. (n.d.) *Overcoming Challenges in Community-Led Total Sanitation*, https://www.tearfund.org/Sites/TILZ/Resources/Publications/Footsteps/Footsteps_91-100/Footsteps_97/Overcoming_challenges_in_Community_Led_Total_Sanitation (accessed 5 July 2018)

Coffey, D., Gupta, A., Hathi, P., Khurana, N., Spears, D., Srivastav, N. and Vyas, S. (2014) 'Revealed preference for open defecation: Evidence from a new survey in rural North India', *Economic and Political Weekly* 49.38, http://www.epw.in/journal/2014/38/special-articles/revealed-preference-open-defecation.html (accessed 22 May 2018)

Cronin, A. (2016) *Sanitation as a Matter of Religious Importance*, Jakarta: UNICEF Indonesia, http://unicefindonesia.blogspot.com/2016/07/sanitation-as-matter-of-religious.html (accessed 22 May 2018)

Edström, J., Hassink, A., Shahrokh, T. and Stern, E. (eds) (2015) 'Engendering men: A collaborative review of evidence on men and boys in social change and gender equality', *EMERGE Evidence Review*, Promundo-US, Sonke Gender Justice and IDS, https://opendocs.ids.ac.uk/opendocs/bitstream/handle/123456789/7059/EMERGE.pdf?sequence=1 (accessed 22 May 2018)

Ekhator, J. and England, P. (2015) *Championing CLTS in Conflict-Affected Communities in Nigeria: Benedict Emori's Story* https://www.globalcitizen.org/en/content/championing-clts-in-conflict-affected-communities/ (accessed 22 May 2018)

Halcrow, G., Rowland, C., Willetts, J., Crawford, J. and Carrard, N. (2010) *Resource Guide: Working Effectively with Women and Men in Water, Sanitation and Hygiene Programs*, Sydney: International Women's Development Agency and

Institute for Sustainable Futures, University of Technology Sydney

Hanchett, S., Krieger, L., Kahn, M.H., Kullmannn, C. and Ahmed, R. (2011) *Long-Term Sustainability of Improved Sanitation in Rural Bangladesh*, Washington, DC: World Bank, https://openknowledge.worldbank.org/handle/10986/17347 (accessed 22 May 2018)

Kamundi, E. and Pigolo, G. (2018) *Lessons Promoting Infant Faeces Management Hygiene Behaviours in PNG*, http://washfutures.com/wp-content/uploads/2018/03/WASH-Futures-2018-Handbook.pdf

Kar, K. with Chambers, R. (2008) *Handbook on Community-Led Total Sanitation*, London and Brighton: Plan International and IDS, http://www.communityledtotalsanitation.org/sites/communityledtotalsanitation.org/files/cltshandbook.pdf (accessed 22 May 2018)

Krukkert, I., da Silva Wells, C., Yubraj, S. and Duwal, M.D. (2010) 'Hygiene promotion for men: Challenges and experiences from Nepal', *Waterlines* 29.4, https://www.developmentbookshelf.com/doi/abs/10.3362/1756-3488.2010.031 (accessed 22 May 2018)

Leahy, C., Lunel, J., Grant, M., and Willetts, J. (2017) *Women in WASH Enterprises: Learning from Female Entrepreneurship in Cambodia, Indonesia and Lao PDR*, Sydney: Institute for Sustainable Futures, University of Technology Sydney, http://enterpriseinwash.info/wp-content/uploads/2017/10/Working-Paper-6_Women-in-WASH-Enterprises.pdf (accessed 22 May 2018)

Maulit J.A. (2015) 'Triggering handwashing with soap in CLTS: Insights on what works from Malawi', *UNICEF Field Note*, http://www.communityledtotalsanitation.org/resource/triggering-handwashing-soap-clts-insights-what-works-malawi (accessed 22 May 2018)

Plan International Australia (2014) *Gender and WASH Monitoring Tool*, https://www.plan.org.au/~/media/plan/documents/resources/gwmt-march-2014.pdf (accessed 22 May 2018)

Routary, P., Torondel, B. and Schmidt, W. (2017) 'Women's role in sanitation decision making in rural coastal Odisha, India', *PLos One* 12.5: e0178042, https://doi.org/10.1371/journal.pone.0178042 (accessed 22 May 2018)

Satyavada, A. (forthcoming, 2018) 'Encouraging men to stop OD: Local efforts that work', *CLTS Knowledge Hub Learning Paper*, Brighton: IDS

SNV (2017) 'Realising sanitation access and usage at anytime, for everyone and everywhere', *Learning Brief*, SNV, Nepal

Thokne, R. (2016) 'Lutyen's zone to be free from open urination', *India Today*, http://indiatoday.intoday.in/story/open-urination-new-delhi-ndmc-lutyens-

zone/1/844768.html

Thys, S., Mwape, K.E., Lefèvre, P., Dorny, P., Marcotty, T., Phiri, A.M., Phiri, I. and Gabriel, S. (2015) 'Why latrines are not used: Communities' perceptions and practices regarding latrines in a Taenia Solium endemic rural area in Eastern Zambia', *PLOS Neglected Tropical Diseases*, 9.3, http://journals.plos.org/plosntds/article?id=10.1371/journal.pntd.0003570 (accessed 22 May 2018)

UNC and World Vision (n.d.) *Processes for Sustainability in Community-Managed Water Systems: Women and Water Management*, https://www.wvi.org/publication/processes-sustainability-women-and-water-management (accessed 22 May 2018)

UNICEF (2010) *Community Led Total Sanitation in Nigeria: Case Studies*, http://gahp.net/wp-content/uploads/2017/10/Institute-for-Development-Studies-Community-Led-Total-Sanitation-in-Nigeria-Case-studies-.pdf (accessed 22 May 2018)

UNICEF (2015a) *Using Social Norms Theory to Strengthen CLTS in Southern Madagascar*, https://www.unicef.org/esaro/UNICEF-FN-CLTS-Madagascar-low-res.pdf (accessed 22 May 2018)

UNICEF (2015b) *Going Beyond ODF: Combining Sanitation Marketing with Participatory Approaches to Sustain ODF Communities in Malawi*, WASH Field Note, March 2015, https://www.unicef.org/esaro/WASH-Field-Malawi-low-res.pdf (accessed 22 May 2018)

Unilever (2017) *More Toilets Used by More People*, https://www.unilever.com/Images/sanitation-behaviour-change-source-book_tcm244-510654_en.pdf (accessed 22 May 2018)

Upadhayaya, V. (2015) 'India tries public shaming to tackle its culture of public urination', *Epoch Times* March 15, http://www.theepochtimes.com/n3/1284605-modi-will-have-to-build-more-urinals-tostop-public-urination-in-india/, accessed 11 February 2018

Venema, V. (2015) *The Unlikely Sanitary Pad Missionary*, http://www.bbc.co.uk/news/magazine-34925238 (accessed 22 May 2018)

Water and Sanitation Program (WSP) (2010) *Global Scaling Up Handwashing Project. Involving Men in Handwashing Behaviour Change Interventions in Senegal*, Washington DC: World Bank https://www.wsp.org/global-initiatives/global-scaling-handwashing-project (accessed 22 May 2018)

Water and Sanitation Program (WSP) (2016) *Consumer Research for Rural Sanitation in Uttar Pradesh May 2016 Key Insights and Next Steps*, Washington DC: World Bank, http://pubdocs.worldbank.org/en/399241490152705598/India-CRRS-UP-

Long-Presentation.pdf
Water Supply and Sanitation Collaborative Council (WSSCC) and Freshwater Action Network South Asia (FANSA) (2016) *Leave No One Behind: Voices of Women, Adolescent Girls, Elderly and Disabled People, and Sanitation Workers*, http://wsscc.org/wp-content/uploads/2016/03/Leave-No-One-Behind-Report-by-WSSCC-and-FANSA-2016.pdf (accessed 22 May 2018)
Water Supply and Sanitation Collaborative Council (WSSCC) (2013) 'As We Grow Up – flipbook', https://www.wsscc.org/resources-feed/as-we-grow-up-flipbook/ (accessed 22 May 2018)
WaterAid (2009) *Sustainability and Equity Aspects of Total Sanitation Programmes: A Study of Recent WaterAid-Supported Programmes in Nigeria*, London: WaterAid
WaterAid (2016) *Exploring Gender Aspects of Community Water, Sanitation and Hygiene in Timor-Leste: A Manual for Facilitating Dialogue between Women and Men in Communities*, London: WaterAid, https://washmatters.wateraid.org/publications/exploring-gender-aspects-of-community-water-sanitation-and-hygiene-in-timor-leste
Willetts, J., Murta, J. and Gero, A. (2016) *Water and Sanitation Entrepreneurs in Indonesia, Vietnam and Timor-Leste: Traits, Drivers and Challenges*, Sydney: Institute for Sustainable Futures, University of Technology Sydney, http://enterpriseinwash.info/wp-content/uploads/2016/06/isf-uts_2016_working-paper-4-traits-drivers-and-barriers_cross-country-review.pdf (accessed 22 May 2018)

## អំពីអ្នកនិពន្ធ

**Sue Cavill** ជាអ្នកជំនាញមិនជាប់កិច្ចសន្យាដែលមានបទពិសោធន៍ក្នុងការអនុវត្ត និងវាយតម្លៃកម្មវិធីទឹកស្អាត និងអនាម័យ និងការស្រាវជ្រាវការវិភាគ និងការផ្សព្វផ្សាយយុទ្ធសាស្ត្រ និងគោលនយោបាយដែលពាក់ព័ន្ធនឹងទឹកស្អាត និងអនាម័យ។

**JoannaMott** ជាអ្នកឯកទេសផ្នែកយេនឌ័រ និងបរិយាប័ន្នសង្គមដែលមានបទពិសោធន៍ការងារជាង ២០ ឆ្នាំលើផ្នែកអភិវឌ្ឍន៍អន្តរជាតិ (ការអភិវឌ្ឍសហគមន៍ យេនឌ័រ និងបរិយាប័ន្នសង្គម និងវិស័យទឹកស្អាត និងអនាម័យ)។

**Paul Tyndale-Biscoe** ជាវិស្វករ និងអ្នកអនុវត្តន៍ផ្នែកអភិវឌ្ឍន៍ដែលមានបទពិសោធន៍ជាង ២០ ឆ្នាំក្នុងការអនុវត្ត ការរចនា និងការវាយតម្លៃកម្មវិធីទឹកស្អាត និងអនាម័យក្នុងតំបន់អាហ្វ្រិក អាស៊ី និងប៉ាស៊ីហ្វិក។

**Matthew Bond** ជាទីប្រឹក្សាទឹកស្អាត និងអនាម័យ ដែលមានបទពិសោធន៍ក្នុងការរចនា ការពិនិត្យតាមដាន និងការវាយតម្លៃ និងចាប់អារម្មណ៍យ៉ាងខ្លាំងលើយេនឌ័រ និងបរិយាប័នសង្គម។

**Chelsea Huggett** ជាប្រធានក្រុមបច្ចេកទេសសមធម៌ និងបរិយាប័នរបស់អង្គការ WaterAid អូស្ត្រាលី ដែលមានឯកទេសផ្នែកយេនឌ័រក្នុងវិស័យទឹកស្អាត និងអនាម័យ ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក។

**Elizabeth Wamera** មានបទពិសោធន៍យ៉ាងច្រើនក្នុងផ្នែកទឹកស្អាត និងអនាម័យ និងបច្ចុប្បន្នជាអ្នកជំនាញបច្ចេកទេសទឹកស្អាត និងអនាម័យរបស់ក្រុមប្រឹក្សាកិច្ចសហការផ្គត់ផ្គង់ទឹក និងអនាម័យ (WSSCC)។

## អំពីកម្រងឯកសារនេះ

នេះជាកម្រងកំណត់សម្គាល់ខ្លីៗដែលផ្តល់ការណែនាំជាក់ស្តែងស្តីពីមធ្យោបាយ និងវិធីសាស្ត្រថ្មីៗ និងការពិចារណាពីបញ្ហាផ្សេងៗទៀត។

យើងខ្ញុំរីករាយនឹងទទួលយកមតិ គំនិត និងការលើកឡើងទាំងឡាយ។ សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋាន ៖ SLH@ids.ac.uk។

## កម្រងឯកសារផ្សេងទៀតដែលបានបោះពុម្ពផ្សាយ

កម្រងឯកសារទាំងអស់អាចរកបានតាមគេហទំព័រ៖
https://sanitationlearninghub.org/series/frontiers-of-sanitation/


**ឯកសារទី ១ ៖** Cole, B. (2013) ‘Participatory design development for sanitation’

**ឯកសារទី ២ ៖** Maulit, J.A. (2014) ‘How to trigger for handwashing with soap’

**ឯកសារទី ៣ ៖** Wilbur, J and Jones, H. (2014) ‘Disability: Making SLH fully inclusive’

**ឯកសារទី ៤ ៖** Cavill, S. with Chambers, R. and Vernon, N. (2015) ‘Sustainability and SLH: Taking stock’

**ឯកសារទី ៥ ៖** House, S. and Cavill, S. (2015) ‘Making sanitation and hygiene safer: Reducing vulnerabilities to violence’

**ឯកសារទី ៦ ៖** Roose, S., Rankin, T. and Cavill, S. (2015) ‘ Breaking the next taboo: Menstrual hygiene within SLH’

ឯកសារទី ៧ ៖ Chambers, R. and Myers, J. (2016) ‵Norms, knowledge and usage′

ឯកសារទី ៨ ៖ Musembi, C. and Musyoki, S. (2016) ‵SLH and the right to sanitation′

ឯកសារទី ៩ ៖ Greaves, F. (2016) ‵SLH in post-emergency and fragile states settings′

ឯកសារទី ១០ ៖ House, S., Cavill, S. and Ferron, S. (2017) ‵ Equality and non-discrimination (EQND) in sanitation programmes at scale′

# ការជំរុញការចូលរួមរបស់បុរស និង ក្មេងប្រុសក្នុងកម្មវិធីអនាម័យ

ការជំរុញការចូលរួមយ៉ាងសកម្ម និងជាវិជ្ជមានរបស់បុរស និងក្មេងប្រុសក្នុងកម្មវិធីអនាម័យជាការពង្រឹងលទ្ធផលដែលមាននិរន្តរភាព និងបង្កើនសក្តានុពលនៃការបែងចែកឡើងវិញនូវបន្ទុកកិច្ចការផ្ទះ និងកិច្ចការមើលថែដែលមិនស្មើភាពពីស្ត្រីទៅបុរស។ ការពិភាក្សាពីយេនឌ័រក្នុងកម្មវិធីអនាម័យ (និងកន្លែងផ្សេងទៀត) ច្រើនផ្តោតលើតួនាទីគោលជំហរ ឬផលប៉ះពាល់លើស្ត្រី និងក្មេងស្រី ប៉ុន្តែឯកសារទី ១១ នៃកម្រងឯកសារ "ព្រំដែននៃកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង" ស្វែងយល់ពីគម្រូឥរិយាបថ និងតួនាទីយេនឌ័ររបស់បុរស និងក្មេងប្រុសក្នុងកម្មវិធីអនាម័យ។ ចំណុចគួរឱ្យចាប់អារម្មណ៍ជាងគេនោះ គឺកម្រិតដែលការជំរុញការចូលរួមរបស់បុរស និងស្ត្រីក្នុងដំណើរការអនាម័យកំពុងធ្វើឱ្យមានការផ្លាស់ប្តូរ ទៅរកសមភាពយេនឌ័រ និងនិរន្តរភាពក្នុងគ្រួសារ និងសហគមន៍ និងកំពុងកាត់បន្ថយវិសមភាពផ្អែកតាមយេនឌ័រ។ ឯកសារនេះផ្តោតលើរបៀបជំរុញការចូលរួមរបស់បុរស និងក្មេងស្រី របៀបកៀរគរពួកគេធ្វើជាសម្ព័ន្ធក្នុងការផ្លាស់ប្តូរលទ្ធផលអនាម័យ និងបញ្ហាដែលពួកគេរួមចំណែក និងកំពុងប្រឈម។



Illustration by Jamie Eke

the sanitation learning hub

វិទ្យាស្ថានសិក្សាអភិវឌ្ឍន៍ (IDS) នៃសាកលវិទ្យាល័យ Sussex, Brighton BN1 9RE
គេហទំព័រ ៖ https://sanitationlearninghub.org/
អ៊ីមែល ៖ SLH@ids.ac.uk
Twitter ៖ @SanitationLearningHub
ទូរស័ព្ទ ៖ +44 (0) 1273 606261
ទូរសារ ៖ +44 (0) 1273 621202

IDS ជាក្រុមហ៊ុនសប្បុរសធម៌ក្រោមការធានាមានកម្រិត ៖ Registered Charity No. 306371; Registered in England 877338; VAT No. GB 350 899914

## ស្វែងយល់បន្ថែមទៀត

ជាវ ព្រឹត្តិប័ត្រកម្មវិធីសហគមន៍ដឹកនាំអនាម័យទាំងស្រុង (SLH ចែករំលែកបទពិសោធន៍របស់អ្នក និងរួមចំណែកដល់គេហទំព័ររបស់ SLH តាមអ៊ីមែល ៖ SLH@ids.ac.uk